# កិច្ចសំភាសន៍របស់លោកតារៀង លាប

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ រៀង លាប

កៈ ចាស!មុនដំបូងសូមជំរាបសួរលោកតា!

ខៈ បាទ!ជំរាបសួរ!

កៈ
ចាសលោកតាអឺ!...នៅក្នុងថ្ងៃនេះចៅមានឪកាសដើម្បីនឹងមកធ្វើការសំភាសន៍ដល់លោកតាផ្ទាល់!
ហើយចៅបានធ្វើការងារស្មាគចិត្តនៅក្នុងគំរោងរបស់ខាងសាលាBYUនៅខាងសហរដ្ឋអាមេរិកណា!លោកតា!...

ខៈ សាធូក!មិនអីនោះទេ!

កៈ
ចាស!ហើយគំរោងមួយនឹងគេជួយចង់ក្រង់ពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាដែលមានអាយុ៣៥ឆ្នាំឡើងអំពីជីវៈប្រវិត្ត
អំពីបទពិសោធន៍ដែលគាត់បានធ្លាប់ឆ្លងកាត់តាំងពីមុនមករហូតដល់ពេលឥឡូវ
ដែលគាត់ធ្លាប់មានបទពិសោធន៍ជីវិតអីគេខ្លះ!ដើម្បីចែកចាយទុកអោយកូនចៅជំនាន់ក្រោយទៀតគេបានស្តាប់ដែរចឹងណាលោកតា!

ចាស!ចឹងលោកតាចឹងនៅថ្ងៃនេះចៅមានឪកាសដើម្បីមកសំភាសន៍ដល់លោកតាចឹង
តើលោកតានឹងអនុញ្ញាតអោយចៅធ្វើការសំភាសន៍លោកតានៅក្នុងថ្ងៃនេះដែរឬទេលោកតា?

ខៈ បាទ!ខ្ញុំនឹងអនុញ្ញាតចៅធ្វើការសំភាសន៍ចុះ!បាទ!

កៈ ចាស!លោកតាចឹងថ្ងៃនេះនឹងគឺជាថ្ងៃទី២៥ខែ៧ឆ្នាំ២០១៨ នឹងហើយ!

ខៈ បាទ!

កៈ ហើយចៅមានឈ្មោះថាហេង សុជីវីជាអ្នកសំភាសន៍ដល់លោកតាផ្ទាល់តែម្តង!

ខៈ បាទ!

កះ ចឹងលោកតាជាដំបូងអីការសំភាសន៍នឹងតើលោកតាមានឈ្មោះអ្វីដែរ?

ខះ តាមកំណើតមកនឹងឈ្មោះរបស់តារៀង លាប។

កះ ចាសលោកតា!ចឹងឈ្មោះរបស់លោកតានេះទាំងនាមត្រកូលអីនឹងម៉ង់ហេសលោកតា?

ខះ នឹងហើយទាំងនាមត្រកូលអីនឹងឈ្មោះ រៀង លាបនឹងនេះនៅក្នុងអត្តសញ្ញាប័ត្រនេះនឹង!

កះ ចាសលោកតា!ហើយអឺ!...ឈ្មោះរបស់លោកតាពិតដែរឬទេលោកតា?

ខះ បាទ!ឈ្មោះនឹងគឺពិតហើយបាទ!

កះ អត់មានដែរនឹងប្រើឈ្មោះអ្វីផ្សេងទេហ៎?

ខះ អត់ដែរនោះទេមានឈ្មោះតែ លាបៗនឹងចឹង។

កះ ចុះចំណែកឯឈ្មោះហៅក្រៅវិញមានឈ្មោះថាលោកតា លាប?

ខះ នឹងហើយ!ហៅថាលោកតា លាបនឹងតែម្ដងនឹង!

កះ ចាស! លោកតាចឹងឈ្មោះនឹងមានអត្តន័យយ៉ាងម៉េចដែរទៅចំពោះលោកតា?

ខះ
អានេះនឹងរឿងអត្តន័យនឹងដូចថាខ្ញុំនឹងពេលនឹងមានចាស់ទុំនឹងគាត់បានដាក់ឈ្មោះនឹងអោយដល់ខ្ញុំនឹងតែម្ដងថា លាបចឹង នឹងហើយ!តាលាបនឹង!

កះ ឪពុកម្ដាយរបស់លោកតាជាអ្នកដែលបានដាក់ឈ្មោះនឹងអោយ!

ខះ បាទ!មានឈ្មោះ លាបនឹងមានលាបមានជ័យអីនឹងចឹងទៅ!
នឹងចំពោះអត្តន័យ!ហេសៗៗៗ!!

កះ ចាសៗលោកតា!ចុះឥឡូវនឹងលោកតាមានព្រះជនបានប៉ុន្មានហើយ?

ខះ ឥឡូវនឹងមានព្រះជន៧៩ព្រះវស្សាហើយ!

កះ អូ!...ចាស!ហើយចឹងលោកតានៅតែមានសុខភាពមាំចឹងហើយមានសុខភាពល្អមើលទៅ!

ខះ បាទ!ចំពោះសុខភាពនឹងវាមិនអីនោះទេរឿងសុខភាពនឹងបាទ!
មានផ្ដាសាយអីនឹងតិចតួចអីនឹងជារឿងធម្មតានោះទេបាទ!

ក៖ ចាស!លោកតាកើតនៅក្នុងឆ្នាំណាដែរ?

ខ៖ ហឺ!...កាលនឹងបានកើតនឹងនៅក្នុងឆ្នាំចរ!

ក៖ ចាស!

ខ៖ កាលនឹងតានឹងកើតនៅឆ្នាំចរនៅក្នុងឆ្នាំ មួយពាន់ប្រាំបួនរយ ប៉ុន្មាននោះទេតាមើលនឹងវាអត់ឃើញ។

ក៖ ចាសលោកតា! នៅក្នុងឆ្នាំ១៩៤៥។

ខ៖ នៅក្នុងឆ្នាំ១៩៤៥ហេស?

ក៖ ចាស!នៅក្នុងថ្ងៃទី៤ ខែ៥។

ខ៖ បាទៗ!

ក៖ ចឹងនៅក្នុងអត្តសញ្ញាប័ត្រនឹងបានត្រូវជាមួយនឹងអាយុពិតនឹងតែម្តង?

ខ៖ នឹងហើយបានត្រូវជាមួយនឹងអាយុនឹងពិតនឹងតែម្តង។ហឹសៗ!

ក៖ អូ!...ចឹងតើលោកតាមានស្រុកកំណើតនឹងនៅឯណាដែរទៅលោកតា?

ខ៖ នុសមើលនៅក្នុងនេះមើល!

ក៖ អូ!...ស្រុកកំណើតគេបានដាក់នៅក្នុងខេត្តអឺ...នៅក្នុងខេត្តព្រៃវែង!...

ខ៖ បាទ!

ក៖ នៅក្នុងភូមិ តាណាល ...

ខ៖ នៅភូមិ តាណាល...

ក៖ នៅក្នុងឃុំ ក្លើងរាយចាស! ស្រុក កញ្ជៀច ចាស!

ខ៖ នៅក្នុងកញ្ជៀក...

ក៖ នៅក្នុងស្រុក កញ្ជៀច!

ខ៖ មិនមែននៅក្នុងស្រុកកញ្ជៀកនោះទេនៅក្នុងស្រុកកញ្ជៀចណា!

ក៖ ចឹងនៅក្នុងស្រុកកញ្ជៀចនឹង គេដាក់នឹង ច តែចំណែកឯកញ្ជៀកវិញ គេដាក់នឹង ក។

ខ៖ ទេនឹងមានតែគេនឹងបានវ៉ែនឹងខុសចុង។

ក៖ ហេសៗ!

ខ៖ ឃើញទេ?

ក៖ ឃើញហើយលោកតានៅក្នុងអត្តសញ្ញាប័ត្រ។

ខ៖ នឹងគេនឹងបានដាក់កញ្ចៀចចឹង?

ក៖ នឹងហើយនឹងច នៅក្នុងអត្តសញ្ញាប័ត្រ!
ចឹងហើយលោតាសព្វថ្ងៃលោកតាមានទីលំនៅនៅឯណាដែរ?

ខ៖ សព្វថ្ងៃនេះនឹងមានទីលំនៅ នៅឯក្នុងវត្តព្រះពុទ្ធនឹង។

ក៖ នៅវត្តព្រះពុទ្ធមានបុណ្យ?

ខ៖ បាទ!

ក៖ ចាស! ចុះទីតាំងនៅឯណាដែរទៅលោកតា?

ខ៖ ទីតាំងនឹងនៅឯស្រុកកំណើតនឹង!

ក៖ អត់នោះទេសព្វថ្ងៃនេះនឹង?

ខ៖ នៅឯវត្តនឹងតែម្តងនៅដល់២៤ម៉ោងនឹង!

ក៖ នឹងហើយ!នៅ២៤ ហេស!

ខ៖ នឹងហើយ!

ក៖ ចាស!លោកតាអឺ!...ប៉ុន្តែទីតាំងនៅក្នុងវត្តនឹងនោះ
តើលោកតាអាចនឹងធ្វើការបញ្ជាក់ទីតាំងបានដែរឬទេ?

ខ៖ វត្តនឹងនៅ នៅនេះ សង្កាត់វាលវ៉ង់ ខណ្ឌ័៧មករា ។

ក៖ ចាសលោកតា!
ចឹងចុះចំពោះសមាជិកនៅក្នុងក្រុមគ្រួសារវិញតើលោកតាមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ សមាជិកនៅក្នុងក្រុមគ្រួសារបងប្អូនរបស់ខ្ញុំនឹងមាន ៦នាក់។

ក៖ ចាស!

ខ៖ ប្រុស ៣ ស្រីហេស!...បងប្អូន៧នាក់ប្រុស៣ ស្រី...ប្រុស៣ស្រី៣។

ក៖ ប្រុស៣នាក់នឹងស្រី៤ បាន បាន៧នាក់លោកតា!

ខ៖ ប្រុស៣ស្រី៤នាក់នឹងហើយបាទ!

ក៖ គាត់មានឈ្មោះអ្វីខ្លះដែរលោកតា?ហើយលោកតាជាកូនទីប៉ុន្មាននៃគ្រួសារ?

ខ៖ មិនបានដឹងថាកូនទីប៉ុន្មាននោះទេហេសៗៗៗ!

ក៖ ហេស!ៗ ពីអីលោកតាមកទីនេះបានយូរហើយ!

ខ៖ មើលបង!...ខ្ញុំជាកូនទី៣។

ក៖ ចាស!

ខ៖ បាទខ្ញុំជាកូនទី៣នឹងបាទ!

ក៖ គាត់មានឈ្មោះអ្វីខ្លះដែរបងប្អូនរបស់លោកតា?

ខ៖ ថាម៉េច ចង់អោយនិយាយនៅក្នុងនឹងតែម្តងហ៎?

ក៖ ចាស!ឈ្មោះរបស់គាត់ណា តើលោកតាមាននៅចាំដែរឬទេ?

ខ៖ នឹងចឹងពេលនិយាយទៅនឹងបានជាប់នៅក្នុងនុងតែម្តងនឹង?

ក៖ ចាស!

ខ៖ អឺ! មានបងទី១ នឹងមានឈ្មោះថា តារៀងឡោម បងទី២មានឈ្មោះថាលោកតា រៀងឡាង
លោកតាទី៣នឹងគឺខ្ញុំនឹងមានឈ្មោះថា រៀង លាប
ដល់មកប្អូនវិញនឹងជាប្អូនទី៤នឹងមានឈ្មោះថា រៀង ថា
ដូចអស់ហើយ!អូ!បាត់បងស្រីនឹងមានម្នាក់ទៀតនឹងមានឈ្មោះថា រៀង លីម នឹង
ហ៎មានបងប្អូនស្រីនឹងមួយនាក់ទៀតនឹងមានឈ្មោះថា រៀង សុម៉ុំ
ហើយនឹងមានប្អូនស្រីនឹងម្នាក់ទៀតនឹងមានឈ្មោះថា រៀងសននឹងហើយអស់ហើយ!

ក៖
ចាសលោកតា!ចឹងលោកតាបងប្អូនរបស់លោកតានៅតាំងពីក្មេងមកនឹងតើលោកតាមានបានចង់ចាំអីគេខ្លះជាមួយនឹងពួកគាត់?

ខ៖ តាំងពីក្មេងនឹងមកនឹង
បានចង់ចាំមកនឹង!នៅបានចង់ចាំនឹងទាំងអស់នឹងនៅបានចង់ចាំនឹងទាំងអស់អត់មានបានស្លាប់អីនោះទេ។

ក៖ ចាស!

ខ៖ នឹងហើយ!

ក៖
ហើយលោកតាកាលនៅពីក្មេងមកនឹងពេលនឹងលោកតាចូលចិត្តលេងអីគេខ្លះជាមួយនឹងពួកគាត់?

ខ៖
អឺស!...ខ្ញុំនឹងដូចជាអត់នឹងមានចំណង់ចំណូលចិត្តនឹងធ្វើអ្វីនោះទេព្រោះអីខ្ញុំនឹងគឺជាកូនអ្នកស្រែនឹងចឹង!ពេលអ្នកស្រែនឹងកាលនុងមានទៅបានអី មិនមែនដូចទេ
អ្នកស្រែនឹងពេលនឹងមានទៅបានល្បែងរបាំងអីនឹងបានលេងអីនឹងគេទេ!
មានតែពេលបានធំដឹងក្ដីឡើងនឹងគេនឹងបានអោយយើងនឹងបានទៅរៀនទៅសូត្រអីនឹងគេនឹងកាលនឹងនុង។

ក៖
ចឹងកាលនឹងលោកតាអត់មានបានចង់ចាំសកម្មភាពីអ្វីគេខ្លះដែរលោកតាបានធ្លាប់នឹងលេងអីជាមួយគ្នាពេលនៅក្មេងនោះទេ?

ខ៖
អត់នោះទេកាលនុងនោះ!កាលនោះនឹងកាលក្នុងសម័យនោះនឹងអត់ទាន់នឹងមានស្អីនឹងសំរាប់លេងដូចជាក្មេងនៅក្នុងសម័យនេះទេក្មួយអើយ! នៅក្នុងសម័យពីសង្គមចាស់នឹងហឺស!

ក៖ ហឺស!

ខ៖
ទើបបានមកដល់ពេលឥឡូវនឹងបានមានលេងល្បែងរបាំងអីនឹងបែបចង់គ្រាប់យ៉ាងតែកាលពី

មុនមកនឹងវាគ្មាននោះទេ! មានតែទៅវាលស្រែនឹងនោះទេកាលនឹងមានតែទៅចាំគោនឹងក្របីនឹងចឹងទៅ!

ក៖ ហឹស!

ខ៖
ព្រោះអីកាលនុងឪពុកម្ដាយនឹងគាត់គឺជាអ្នកដែលបានធ្វើស្រែនឹងចឹងណាកាលនុង!ចឹងកាលនុងមានអីពេលដែលបានថ្ងៃទៅបន្តិចចឹងទៅបានគាត់អោយទៅមើលក្របីនឹងមើលគោនឹងហើយដល់ពេលថ្ងៃបានបន្តិចនឹងចឹងទៅបានទៅរៀនអីនឹងចឹងទៅកាលនុងនោះចឹងឯង!
ហើយពេលដែលបានមកពីរៀនវិញនឹងបានទៅមើលគោក្របីអីនឹងចឹងទៀតចឹងទៅ!
ម្ដាយឪនឹងគាត់នឹងបានទៅដកនឹងទៅស្ទូងនឹងកាលនឹងនុងអត់មានអីនឹងទេកាលនៅក្នុងសម័យកាលពីជំនាន់ដើមនឹងមកនឹងនុង! កាលនៅជំនាក់នឹងនោះខ្ញុំនឹងជាអ្នកស្រែនឹងសុទ្ធហើយ។

ក៖ ចាស! ចឹងលោកតាឥឡូវនឹងពួកគាត់ទាំងអស់គ្នានឹងនៅឯណាខ្លះដែរលោកតា?

ខ៖ នៅឯស្រុកកំណើតនឹងបងប្អូន!

ក៖ ទាំងអស់តែម្ដងទាំងបងប្អូនទាំង៦នាក?

ខ៖ នឹងហើយ!បងប្អូននឹងនៅក្នុងឯស្រុកកំណើតនឹងទាំងអស់គ្នានឹងតែម្ដង!

ក៖ នៅជាមួយនឹងទាំងបងប្អូន៦នាក់?

ខ៖ អូ!ៗ...មានរស់នៅបានបែកគ្នានឹងបានខ្លះដែរនៅខាងព្រៃនៅខាងជើងមាត់នឹងកាលនុង។

ក៖ ចឹងគាត់បានប្រកបការងារអ្វីខ្លះដែរ?

ខ៖ គាត់នឹងបានធ្វើការងារខាងចំការនឹង!គាត់នឹងមានចំការនឹងធ្វើ
ទៅដាក់ដាំចំការកៅស៊ូនឹងបានខ្លះចឹងទៅបានទៅដាក់ដាំចំការ
ម្រិចអីនឹងបានខ្លះចឹងទៅ!មុខរបរគាត់នឹង!ហើយចឹងមានបងប្រុសគាត់នឹងមួយនឹងអានឹងគេនឹងមានចំការដំឡូងមានចំការសណ្ដែកនឹងហើយនឹងមានចំការកៅស៊ូ។

ក៖ ចាស!

ខ៖ នឹងហើយមានចំការស្វាយច័ន្ទី។
ចំណែកឯខាងខ្ញុំនេះវិញនឹងអត់មានចំការនោះទេនៅតែវត្តនឹងទេហេសៗ!

ក៖ ចាសលោកតា!

ខ៖ គ្រាន់តែចឹង!

ក៖ ចឹងឪពុកម្ដាយរបស់លោកតាវិញគាត់មានឈ្មោះអ្វីគេដែរ?

ខ៖ អូ!...ពួកគាត់នឹងបានស្លាប់អស់ទៅយូរណាស់ហើយពួកគាត់នឹង!

ក៖ ចាស!

ខ៖ ឪពុកខ្ញុំនឹងគាត់មានឈ្មោះថា តា រៀង ហើយនឹងម្ដាយរបស់ខ្ញុំនឹងគាត់មានឈ្មោះថា យាយលាងនឹង!ប៉ុន្តែគាត់នឹងបានស្លាប់នឹងអស់ទៅបាត់ទៅហើយ!

ក៖ ហឺ!...

ខ៖
គាត់នឹងបានស្លាប់នឹងតាំងពីខ្ញុំនឹងនៅក្នុងជំនាន់ពពតនឹងកាលនឹងប៉ុន្តែពេលដែលគាត់នឹងបានស្លាប់ទៅនឹងកាលនឹងគាត់បានស្លាប់ទៅតាមជីវិតដំណាលរបស់គាត់នឹងមកនោះទេអត់មានពីណាមកធ្វើបាបធ្វើពានោះទេណា!កាលនុងគាត់នឹងស្លាប់នឹងទៅតាមជំងឺរោគានឹងជង្កាតអីនឹងជាធម្មតានោះទេ!

ក៖ តាំងឪនឹងតាំងម្ដាយរបស់លោកតា?

ខ៖
បាទ!ៗគាត់នឹងបានស្លាប់នឹងបាត់ទៅហើយទាំង២នាក់នឹង!ប៉ុន្តែគ្រាន់តែថានៅក្នុងជំនាន់នឹងកាលនឹងគាត់នឹងបានស្លាប់ទៅនឹងដោយសារតែជំងឺអីនឹងជាធម្មតានោះទេកាលនៅក្នុងជំនាន់នឹងណាអត់មានគេនឹងបានយកគាត់នឹងទៅធ្វើបាបធ្វើពាអីនឹងគឺអត់មាននោះទេ!

ក៖ ចាស!ចឹងកាលនឹងនុងគាត់មានអាយុបានប៉ុន្មានដែរលោកតា?

ខ៖
យី!កាលនុងគាត់នឹងមានអាយុនឹងបានច្រើននឹងដែលនឹងកាលនុងនោះ!ព្រោះអីកាលនុងនោះនៅក្នុងឆ្នាំ១៩៧២នឹងគាត់នឹងស្លាប់ហើយមានមកដល់គាត់នឹងស្លាប់ជាង៦០ហើយនឹងឪវិញនឹងគាត់បានស្លាប់នៅក្នុងអាយុជាងបាន៧០ឆ្នាំ។ដូចជានៅក្នុងឆ្នាំ៧២ទៅ៧៣អីនឹងតែចំណែកខាងម្ដាយនឹងវិញនឹងគាត់មានអាយុនឹងបានប្រហែលជាបាន៦០ជាងនឹងបានលើស!ប៉ុន្តែនឹងវា

មិនបានដឹងអោយប្រកត់នឹងបាននៅក្នុងឆ្នាំណានោះទេពេលនឹងដែលគាត់នឹងបានស្លាប់ទៅនឹងនោះ!

ក៖ ចាស!កាលនុងគាត់នឹងកើតនឹងនៅក្នុងឆ្នាំណាដែរលោកតាមានបាននៅចង់ចាំដែរឬទេ?

ខ៖ អត់មានបាននៅចាំឆ្នាំកំណើតរបស់គាត់នឹងនោះទេ។

ក៖
ចុះចឹងលោកតាមានបានដឹងថាគាត់នឹងបានកើតនៅឯណានោះទេ?ស្រុកកំណើតរបស់ឪពុកម្ដាយរបស់លោកតាណា?

ខ៖ ស្រុកកំណើតរបស់ឪពុកម្ដាយខ្ញុំនឹងគាត់នឹងបានកើតនៅឯក្នុងភូមិ
តាណាលនឹងតែម្ដងនឹង!

ក៖ ចឹង!

ខ៖ បាទ!

ក៖ ទាំង២នាក់តែម្ដងលោកតានុះ?

ខ៖ បាទ!គាត់នឹងបានកើតនៅក្នុងភូមិនឹងតែម្ដង។

ក៖
ចុះចំណែកឯឪពុករបស់លោកតានៅកាលពីមុននឹងគាត់នឹងបានធ្វើអ្វីគេដើម្បីនឹងចិញ្ចឹមជីវិត?

ខ៖
អូ!...ឪពុកម្ដាយរបស់ខ្ញុំនឹងកាលនុងខ្ញុំនឹងមិនបាននឹងធ្វើអីនឹងទេក្រៅពីមុខរបស់ធ្វើស្រែចំការនោះទេគ្រួសាររបស់ខ្ញុំនឹងគឺបានធ្វើស្រែចំការនឹងសុទ្ធតែម្ដង!បាទ!

ក៖ ចុះគាត់ជាមនុស្សបែបណាដែរទៅលោកតា?

ខ៖ ហេស!

ក៖ ឪពុករបស់លោកតាជាមនុស្សបែបណាដែរ?គាត់កាច គាត់ស្លូត?

ខ៖ អត់នោះទេគាត់នឹងជាមនុស្ស
សភាវាសានោះទេអត់នឹងមានជីវៈប្រវិត្តកាចឃោឃៅនោះទេបាទ! អត់នោះទេ។

កៈ ហឺ! ចុះម្ដាយរបស់លោកតាវិញ?

ខៈ ម្ដាយរបស់ខ្ញុំនឹងក៏ចឹងដែរអត់ថាមានជាអ្នកដែលបានស៊ីផឹកអីនោះទេ អត់មានថាជាអ្នកដែលកោងកាចអីនឹងនោះទេគាត់គឺជាមនុស្សសុភាពនឹងរាបសា ដើម្បីនឹងចិញ្ចឹមកូននឹងចិញ្ចឹមចៅនឹងអត់មានអីនោះទេបាទ!

កៈ ចាស!ចុះហើយគាត់ខំប្រឹងធ្វើការងារអ្វីខ្លះដែរដើម្បីនឹងចិញ្ចឹមជីវិត?

ខៈ
បាទ!ចិញ្ចឹមជីវិតចិញ្ចឹមកូននឹងមានតែការងារធ្វើស្រែចំការនឹងហើយបាទ!អត់នឹងមានទៅធ្វើអ្វីផ្សេងនោះទេកាលនឹងនៅឯស្រុកខ្ញុំនឹងអត់មានគេទៅធ្វើចំការនោះទេនៅខាងស្រុករបស់ខ្ញុំ។

កៈ អូ!...

ខៈ បានធ្វើការងារនឹងតែស្រែនោះទេបាទ!

កៈ
ចាស!ចឹងលោកតាមានបានចង់ចាំរឿងអីគេខ្លះជាមួយនឹងឪពុកម្ដាយរបស់លោកតាតាំងពីលោកតានៅកាលពីសម័យនៅកាលពីក្មេងៗ?

ខៈ ខ្ញុំនឹងកាលនឹងបានទៅរស់នៅជាមួយនឹងឪពុកម្ដាយនឹងកាលនុងខ្ញុំនឹងមានការចង់ចាំឈឺចិត្តស្អិតទ្រូងនឹងមើលឃើញតែគាត់នឹងម្ដាយឪពុកនឹងគាត់គឺជាអ្នកដែលបានធ្វើស្រែនឹងបានឃើញគាត់នឹងវាលំបាកនឹងមានជីវៈភាពនឹងក្រីក្រ។មួយឆ្នាំនឹងណានឹងក៏បានមើលឃើញគាត់នឹងក៏ធ្វើការងារស្រែមួយឆ្នាំនឹងណានឹងគ៏បានឃើញគាត់នឹងទៅធ្វើស្រែរហូតមកដល់ពេលដែលខ្ញុំនឹងមានវ័យបានវត្តត:ណាកាលនឹងអាចនឹងរៀនទៅរៀនទៅសូត្រអីនឹងបានហើយនឹងបានគាត់បានបីបាច់នឹងថែរក្សាអោយទៅរៀននឹងទៅសូត្រចឹងទៅ!ហើយនឹងពេលនឹងខ្ញុំនឹងបានពេញវ័យនឹងឡើងនឹងខ្ញុំនឹងបានមើលឃើញតែគាត់នឹងចឹងទៅ!ក៏ខ្ញុំនឹងបានខំប្រឹងតស៊ូនឹងអោយបានរៀនសូត្របានចេះចាំនឹងបានបន្តិចបន្តួចនឹងចឹងទៅក៏រៀបចំអោយមានគ្រួសារនឹងចឹងទៅហើយកាលនឹងគាត់នឹងបានរៀបចំខ្ញុំនឹងអោយមានគ្រួសារនឹងកាលនឹងខ្ញុំនឹងក៏មានរកមធ្យោបាយនឹងដើម្បីនឹងរកស៊ីសំរាប់នឹងដំណើរជីវិតរបស់ខ្ញុំនឹងចឹងទៅណា!ដើម្បីអឺ!..អោយបានរួចផុតចាក់ទុកនឹងពីការធ្វើការងារស្រែអីនឹងចឹងទៅ។ បាទ!នឹងហើយ!

កៈ
ហឺ!...ចាសលោកតា!ចឹងកាលពីនៅជីវិតពីមុននឹងដែលលោកតានៅក្មេងៗនឹងពេលនឹងលោក

ឪពុកនឹងអ្នកម្ដាយរបស់លោកតាកាលពីមុននឹងមកនឹងតើគាត់មានបានធ្លាប់ប្រាប់ពីជីវិតរបស់គាត់នឹងតាំងពីមុននឹងមកដែរឬទេលោកតា?

ខ៖
អឺ!..កាលនឹងគាត់នឹងបានធ្លាប់នឹងប្រាប់ជីវិតរបស់គាត់នឹងបានដែរនឹងណាថាកូនអើយណា! ម៉ែឪនឹងគាត់នឹងបានកើតនឹងមកបានមើលឃើញនឹងតែស្រែណា
ចឹងមកដល់ពេលចឹងម្ដាយឪអោយខំប្រឹងរៀននឹងអោយសូត្រចឹងណាទៅដើម្បីថាអាចនឹងបានចេះដឹងចឹងទៅអាចនឹងបាន!
ពេលនឹងដែលថាបានរៀនសូត្រនឹងចេះដឹងចឹងទៅណាអាចនឹងបានទៅធ្វើការងារអីនឹងបានចេះអីចឹង!គ្រាន់នឹងបានចិញ្ចឹមជីវិតនឹងអីចឹងទៅណាអោយវានឹងអាចនឹងបានផុតពីស្រែពីភ្លឺអីនឹងចឹងទៅណា។
ចឹងកាលនៅជាមួយនឹងគាត់នឹងកាលនឹងគាត់នឹងបានទូន្មានយើងនឹងតែប៉ុណ្ណឹងនោះទេកាលនុងថាគាត់នឹងវាពិបាកនូវការងារធ្វើស្រែនឹងព្រោះអីអ្នកធ្វើស្រែនឹងវាពិបាកណាស់ណា
ចឹងថាអ្នកធ្វើការងារស្រែនឹងវាពិបាកណាស់នឹងហើយ!

ក៖ ចាស!

ខ៖ តែប៉ុណ្ណឹងនោះទេគាត់បានអប់រំទូន្មាននឹងដល់កូនចៅនឹងអោយបានខំ
ប្រឹងរៀនសូត្រនឹងចឹងទៅគ្រែងឡោងបាននឹងចេះដឹងនឹងគេ។

ក៖ ចាស!

ខ៖ អឺយ!

ក៖ លោកតាខាងបងប្អូនជីដូននឹងជីតារបស់លោកតានឹងគាត់មានឈ្មោះអ្វីគេដែរ?

ខ៖ អូ!...ឪម្ដាយនឹងខាង...ឪពុកខាងឪពុកនឹងគាត់មានឈ្មោះថា លោកតា
ម៉ៅ។គាត់នឹងជាជនជាតិលាវ។

ក៖ អូ!...

ខ៖ ហើយចឹងខាងម្ដាយនឹងគាត់មានឈ្មោះថា លោកតា គួង
នឹងគាត់គឺជាជនជាតិខ្មែរយើងនឹងនោះទេ។

ក៖ អូ!

ខ៖
នឹងឪពុកខាងម្ដាយចំណែកឯឪពុកខាងឪពុកតាម៉ៅនឹងគាត់នឹងឪពុកខាងឪពុកនឹងកាលនឹងគាត់ជាជនជាតិលាវនឹងចឹងកាលនឹងគាត់នឹងរសាត់ពីខាងប្រទេសលាវនឹងបានមករស់នៅនឹងនៅៗចឹងទៅហេស!

ក៖ នៅឯខេត្តណាដែរ?នៅឯព្រៃវែង?

ខ៖
ទេខ្ញុំនឹងមិនអាចនឹងដឹងទេ!ខ្ញុំនឹងមិនបានដឹងថាគាត់នៅក្នុងខេត្តឯណានោះទេតែពេលសម័យកាលពីដើមនឹងគាត់បានមករស់នៅឯខេត្តព្រៃវែងយើងនឹង!នៅឯខេត្តព្រៃវែងនឹងតែពេលនឹងខ្ញុំនឹងបានដឹងត្រឹមថាគាត់នឹងជាជនជាតិលាវលោកតានឹង។កាលនឹងខ្ញុំនឹងមិនបាននៅទាន់គាត់នោះទេពេលនឹងខ្ញុំនឹងដឹងថាជីតារបស់ខ្ញុំនឹងគាត់ជាជនជាតិលាវ។

ក៖ ចាស!

ខ៖ គាត់នឹងចូលចិត្តហូបប្រហុកនឹងបានដឹងថាលាវនឹង!ហេសៗៗ!

ក៖ ចឹង!ហេស!ៗ

ខ៖ហេសៗ!លាវនឹងកាលនឹងនុងគេចូលចិត្តហូបប្រហុកណាស់ណា!

ក៖ ចាស!

ខ៖ អឺ!

ក៖ ជីដូនជីតារបស់ម្ដាយរបស់លោកតាវិញ?

ខ៖
អូ!ចំពោះជីដូនជីតាខាងម្ដាយនឹងវិញនឹងគាត់នឹងបាននៅឯស្រែនឹងនោះទេអត់អីនោះទេព្រោះអីគាត់នឹងមានសញ្ញាជាតិនឹងជាខ្មែរយើងនឹងជាធម្មតានោះទេអត់អីនោះទេ!

ក៖ ចុះគាត់មានឈ្មោះអ្វីគេខ្លះដែរ?

ខ៖ អូ!...ឈ្មោះរបស់គាត់នឹងមានឈ្មោះលោកឪពុកគាត់ខាងម្ដាយរបស់ខ្ញុំនឹងមានឈ្មោះថាលោកតា គួងនឹងហើយនឹងម្ដាយនឹងមានឈ្មោះថាលោកយាយសំ
នឹងត្រូវជាឪពុកម្ដាយខាងម្ដាយខ្ញុំនឹងណា!មានឈ្មោះថាលោកតាគួងនឹងលោកយាយសំនឹង!

កៈ ចាស!

ខៈ ហើយនឹងខាងឪពុករបស់ខ្ញុំនឹងគាត់មានឈ្មោះថាលោកតាម៉ៅនឹងលោកយាយម៉ង។

កៈ អូ!ចាសចឹងកាលនឹងលោកតាមានបាននៅទាន់ពួកគាត់ដែរឬទេ?

ខៈ អត់នឹងបានកើតទាន់ពួកគាត់នឹងផង!

កៈ ហឺ!ចុះលោកតាបានដឹងថាគាត់បានកើតនឹងនៅក្នុងឆ្នាំណាអីដែរឬទេ?

ខៈ មិនបាននឹងដឹងនោះទេ។ហេសៗ!

កៈ ចុះគាត់បានកើតនឹងនៅទីណាអីនឹង?

ខៈ
ដឹងបានត្រឹមថាគាត់នឹងបានកើតនៅក្នុងកន្លែងនុងតែម្តងព្រោះអីពេលដែលខ្ញុំនឹងបានដឹងក្តីអីនឹងបានមកនឹងកាលនឹងខ្ញុំនឹងបានមើលឃើញគាត់នឹងនៅឯណុងតែម្តងនឹងចឹង។

កៈ ចុះលោកតាមានធ្លាប់បាននឹងដឹងរឿងអីគេខ្លះពីពួកគាត់នឹងដែរឬទេ?

ខៈ
ដឹងពីរឿងជីវៈប្រវិត្តរបស់ពួកគាត់នឹងបានទេព្រោះអីពេលដែលខ្ញុំនឹងបានដឹងក្តីនឹងឡើងនឹងបានមើលឃើញថាគាត់នឹងបានរស់នៅកន្លែងនឹងបានស្រាប់នឹងតែម្តងនឹងហើយបានធ្វើស្រែនឹងតែម្តង!បានធ្វើស្រែនឹងធ្វើចឹង!ព្រោះអីនៅឯកន្លែងនៅឯខាងនឹងអត់នឹងមានចំការអីនឹងនោះទេណា!អត់មានចំការនោះទេមានតែស្រែនឹងនោះទេមួយរដូវៗនឹងមានតែស្រែនោះទេចឹងពេលដែលបានផុតការធ្វើការងារស្រែនឹងចឹងទៅ!...អឺ!ដូចជាបានដឹងហើយអ្នកស្រែពេលទំនេរចឹងទៅ!មិនមែនដូចជាពេលឥឡូវនឹងមានការងារនឹងបានវិលវង្វង់នឹងចឹងនោះទេកាលពីដើមនឹងនោះ។

កៈ ចាស!

ខៈ ហេស!

កៈ ចឹងកាលពីមុនដំបូងនឹងក្រុមគ្រួសាររបស់លោកតា
នៅខេត្តនឹងបានអស់រយៈពេលនឹងបាននៅយូរនឹងបានប៉ុន្មានដែរទៅ?

ខៈ អូ!...អត់ដឹងនោះទេពេលនឹងនៅទីនុងនឹងរហូតនឹងមកនឹងនៅបានយូរហើយ!ហេស!

ក៖ ហេស!

ខ៖ នៅឯខេត្តព្រៃវែងនឹងខ្ញុំនឹងជាអ្នកស្រែនឹង។

ក៖ អូ!យូរមកហើយតាំងពីពេលដែលបានដាច់ជំនាន់អាពតនឹងបានលោកតា...

ខ៖
បាទ!នឹងហើយតាំងពីពេលដែលបានបែកអាពតនឹងមកនឹងបានមានកូនចៅនឹងបានចែកនឹងវែកញែកអីនឹងចឹងទៅណាមានកូនចៅនឹងអាខ្លះនឹងត្រូវទៅនេះចឹងទៅនោះអីនឹងចឹងទៅណាកាលនុង!

ក៖ ចាស!ចឹង!...

ខ៖
អាខ្លះនឹងចឹងវាបានទៅរស់នៅឯខេត្តក្រៅអីនឹងទៅចឹងអាខ្លះទៀតនឹងបានទៅនៅឯស្រុកនេះអីនឹងណាបាននៅក្បែរៗនឹងអីនឹងនៅក្នុងប្រទេសនៅក្នុងខេត្តអីនឹងបានជាមួយនឹងគ្នាអីនឹងមកចឹងទៅណា!

ក៖ ចាស!

ខ៖ នឹងហើយ!

ក៖
ចឹងនឹងបានត្រឹមតែពេលនៅក្នុងជំនាន់អាពតនឹងមកនោះទេដែលថាក្រុមគ្រួសាររបស់លោកតាបានបែកបាក់គ្នានឹងបានទៅនៅឯនេះទៅនៅឯនោះចឹងទៅ!

ខ៖
នឹងហើយ!នៅដល់ពេលនៅក្នុងសម័យអាពតនឹងនោះទេដែរថាគ្រួសាររបស់ខ្ញុំនឹងយើងនឹងបានបែកបាក់គ្នាហើយនឹងពេលយើងនឹងបានរៀបចំអោយមានក្រុមគ្រួសារនឹងចឹងទៅបានជាយើងនឹងបានបែកបាក់គ្នានឹងចឹងទៅបាទ!

ក៖ អូ!

ខ៖
ចឹងពេលនៅក្នុងជំនាន់ពពតនឹងនៅមានអីនោះទេកាលនឹង!បាទ!ពេលនឹងយើងនឹងបានរសាត់នឹងរដែតទៅនឹងអាខ្លះចឹងទៅមានគ្រួសារទៅ

ហើយអាខ្លះចឹងគេនឹងមានក្រុមគ្រួសារអីនឹងបានចេញទៅនៅឯនុសចឹងទៅតាមដំណើរជីវិតនឹងបានរៀងៗខ្លួនអីនឹងចឹងទៅ!

ក៖
ចាស!លោកតាហើយចឹង!កាលនឹងនុងលោកតាមានបាននឹងរៀបអាពាហ៍ពិពាហ៍ដែរឬទេនៅក្នុងសម័យនុង?

ខ៖ បាទ!កាលនៅក្នុងជំនាន់របស់ខ្ញុំនឹងបានរៀបអាពាហ៍ពិពាហ៍នឹងបានត្រឹមត្រូវល្អណាស់! ទៅតាមប្រពៃណីព្រះពុទ្ធសាសនានឹងបានរៀប....

ក៖ អូ!...

ខ៖ យើងនឹងបានរៀបអាពាហ៍ពិពាហ៍នឹងត្រឹមត្រូវតាមលក្ខណៈប្រពៃណី។

ក៖
ឪពុកម្ដាយគាត់ជាអ្នកដែលបានទុកដាក់នឹងអោយលោកតាឬក៏កាលនឹងលោកតាបានស្រលាញ់គ្នា?

ខ៖
បាទៗ!កាលនឹងឪពុកម្ដាយនឹងគាត់នឹងបានជាអ្នកដែលរៀបចំទុកដាក់នឹងអោយនឹង!ឪពុកម្ដាយនឹងគាតនឹងបានជាអ្នកដែលបានរៀបចំទុកដាក់អីនឹងអោយ!

ក៖ ចុះលោកតាបានធ្លាប់នឹងបានស្គាល់លោកយាយបានពីមុននឹងដែរឬទេ?

ខ៖ ហាស?

ក៖
លោកតាមានបានធ្លាប់បានស្គាល់លោកយាយមកនឹងពេលដែលមិនទាន់បានរៀបការនឹងដែរឬទេ?

ខ៖ ហាស!លោកយាយអីគេ!លោកយាយ...

ក៖ លោកយាយប្រពន្ធរបស់លោកតា!

ខ៖ អូ!...ម្ដាយរបស់ប្រពន្ធរបស់ខ្ញុំនឹងបានស្គាល់!ៗៗ

កៈ មិនមែននោះទេមិនមែនម្តាយរបស់ប្រពន្ធលោកតានោះទេលោកតា លោកយាយដែលត្រូវជាភរិយារបស់លោកតាណា!

ខៈ
មិននោះទេ!អូ!...មិនៗគ្រាន់តែបានលឺឈ្មោះនឹងនោះទេមិនបាននឹងដឹងឈ្មោះទេព្រោះអីគាត់នឹងបានស្លាប់អស់ទៅហើយ!យាយតានឹងខាងគ្រួសាររបស់ខ្ញុំនឹងណា!កាលនឹងបានធ្លាប់តែនឹងបានលឺឈ្មោះនឹងតែមិនដែរបានមើលឃើញនឹងស្គាល់នោះទេ បាទ!

កៈ ប្រពន្ធរបស់លោកតាមានឈ្មោះអ្វីដែរ?

ខៈ បាទ!គ្រួសាររបស់ខ្ញុំ អឺ!...យាយនៅយៀប តារៀងលាបនឹងយាយ នៅយៀប។

កៈ អូ!...ចាស!

ខៈ បាទ!

កៈ
ចឹងលោកតាកាលនឹងលោកតាបានស្គាល់គ្នានឹងមុននឹងរៀបការនឹងឬក៏យ៉ាងណាដែរទៅលោកតា?

ខៈ
បាទ!មុននឹងបានរៀបការនឹងកាលនឹងវាអត់នឹងដែលនឹងបានឃើញមុខគ្នាផងនឹងកាលនុងពេលនឹងយូរៗនឹងបាន!...ពេលដែលម្តាយនឹងឪនឹងគាត់នឹងបានរៀបចំទុកដាក់នឹងអោយនឹងកាលនឹងយើងនឹងក៏បានមើលឃើញនឹងគ្នាអីនឹងយើងនឹងក៏...បានប្រគល់ខ្លួននឹងបានប្រគល់ប្រាណអីនឹងបានអោយគ្នាអីនឹងទៅ!មិនមែនដូចជាពេលនៅក្នុងពេលសម័យនឹងឥឡូវនឹងនោះទេអត់នោះទេកាលនឹងយើងនឹងបាននៅលើម្តាយនឹងឪនោះទេ!នឹងគាត់នឹងបានជាអ្នកដែលបានរៀបចំនឹងអោយនឹងកាលនឹងអត់មានថាទៅ
ដូចជាពេលនៅក្នុងសម័យឥឡូវនឹងនេះនឹងទាល់តែកូនចៅនឹងបានត្រូវគ្នានឹងបានបាននោះទេកាលនឹងពីសម័យមុននឹងបានបានរៀបចំទុកដាក់នឹង!

កៈ ចាស!

ខៈ
កាលនឹងនុងគាត់នឹងបានចង្អុលទិសនឹងដៅអីនឹងថាបានទៅយកកូនអ្នកនេះទៅយកកូនអ្នកនោះអីនឹងចឹងទៅកាលនុង!ថាគាត់នឹងបានមើលឃើញអីនឹងចឹងទៅកាលនឹងគាត់នឹងក៏បាន

ធ្វើការទំនាក់ទំនងអីនឹងចឹងទៅកាលនុង!យើងនឹងក៏បានទៅតាមដំណើររបស់គាត់អីនឹងចឹងទៅកាលនឹងនុងអត់ថាមានអីនោះទេ!អត់ថាមានតែស្រាច់តែនឹងកូននឹងថាទៅឯណាខាងណាអីនឹងកាលនឹងនុងចឹងអីអត់មាននោះទេ!

ក៖ ហេស!ចាសលោកតា!ហេសៗ!

ខ៖ ខ្ញុំនឹងនិយាយត្រង់កាលនឹង!ចឹងមែនតើ!អត់កុហុសនោះទេ។

ក៖ ចាស!នឹងហើយលោកតាកាលនឹងខ្ញុំនឹងបានលឺចាស់!ៗនឹងប្រាប់ដូចលោកតានឹងចឹងដែរ!

ខ៖ បាទ!

ក៖ ចឹងកាលនុងលោកតាបានរៀបការនៅ នៅណាដែរ?

ខ៖ អូ!...នៅពេលកាលនុងតានឹងបានការនៅក្នុងឆ្នាំ១៩៦៩
ដូចជានៅក្នុងឆ្នាំ១៩៦៨នឹងហើយកាលនឹងនៅក្នុងឆ្នាំ១៩៦៩ចុះព្រោះអីពេលនឹងបានជិតនឹងបានដាក់នៅក្នុងឆ្នាំ១៩៦៨ទៅហើយ។
ចូល១៩៦៩នឹងហើយព្រោះអីពេលនឹងយើងនឹងបានរៀបការនឹងបានហើយនឹងបានតែ១ឆ្នាំនោះទេបានចូល...ស្រុករបស់យើងនឹងបានប្រែប្រួលនឹងតាំងពីពេលដើមនឹងមកម្លេះ។

ក៖ អូ!...លោកតាតើការ ការលោកតាពេលមុននឹងមានហែលជំនួននឹងដែរឬទេ?

ខ៖
មានៗកាលការតាកាលពីនៅក្នុងសម័យមុននឹងមាននៅគេហែលជំនួននឹងទៅតាមប្រពៃណីអីនឹងចឹងទៅ!មានហែលកំណត់អីនឹងបានដូចគ្នាអីនឹងបាទ!

ក៖
ចឹងលោកតាអាចនឹងប្រាប់ដល់ខ្ញុំនឹងបានដែរឬទេថាពេលដែលលោកតាបានជួបនឹងលោកយាយមុនដំបូងនឹងនៅក្នុងពេលណាដែរ?

ខ៖
ហេសៗ!កាលនៅពេលមុនដំបូងនឹងខ្ញុំនឹងមិនដែរនឹងបានជួបគាត់នឹងផងគ្រួសាររបស់ខ្ញុំនឹងណា
គ្រាន់តែពេលនឹងយើងនឹងបានធ្វើការសំណោសសំណាលនឹងចឹងថាយាយតានឹងបានប្រាប់ថាកូននេះនឹងចឹងគេនឹងសមរម្យអីនឹងចឹងទៅគាត់នឹងក៏បានទំនាក់ទំនងអីនឹងចឹងនោះទេ!ចឹងទា

ល់តែដល់ពេលថ្ងៃហៃលជំនួនហើយនឹងហើយឹងបានយើងនឹងបានឃើញគ្នាអីនឹងចឹងតែម្ដងនោះទេហេសៗៗ!ហេស!អានឹងតានិយាយនឹងតាសច្ចៈធម៌នឹងទេណា!

ក៖ ចាស!

ខ៖

មិនដែរនឹងបានឃើញគាត់នោះទេកាលនឹងយើងនឹងចេះនឹងបានធ្វើការសំណោសសំណាលអីនឹងចឹងនោះទេកាលនុងចឹង!

ហើយចឹងកាលនុងគាត់នឹងបានចង់ណាស់ថាអោយតែស្ដីដណឹងកូននេះកូននោះអីនឹងចឹងអោយចឹងទៅ!ហើយគាត់នឹងបានមកសួរយើងនឹងថាព្រមឬក៏មិនព្រមអីនឹងចឹងទៅ!

ចឹងហើយពេលដែលថាខ្ញុំនឹងបានព្រមប្រៀននឹងហើយនឹងចឹង!គាត់នឹងក៏បានរៀបចំតាមដំនៀលដំណងរបស់យើងនឹងមកចឹងទៅ។

កាលនឹងនុងខ្វះនឹងមិនដែរនឹងបានមើលឃើញគ្នាអីនឹងបានមកដែរផងនឹងកាលនឹងនុង។

ក៖ ចាស!

ខ៖

ទាល់តែពេលដែលបានស៊ីជំនួនអីនឹងបានហើយនឹងបានជាយើងបានមើលឃើញគ្នានៅពេលនឹងគេនឹងបានហៅមកគ្រូបអោយគ្នានឹងបានជាយើងនឹងបានឃើញគ្នានឹងនៅថ្ងៃនឹងតែបន្ដោយនឹង។ហេសៗ!

ក៖

ចាស!ចឹងសព្វថ្ងៃនេះនឹងលោកតាចេះអានចេះសរសេរភាសាខ្មែររបស់យើងនឹងបានល្អដែរឬទេ?

ខ៖

បាទ!នៅពេលសព្វថ្ងៃនេះនឹងអឺ!...កាលនឹងខ្ញុំនឹងបានរៀននឹងកាលនៅពីសម័យកាលពីមុននឹងមកនឹងកាលនឹងខ្ញុំនឹងបានរៀនត្រឹមថ្នាក់ទី២នឹងកាលនឹងចឹងមកនឹងកាលនឹងខ្ញុំនឹងបានចេះភាសាបារាំងនឹងនៅសម័យកាលនុងណា!

ចឹងកាលពីសម័យកាលពីមុននឹងខ្ញុំនឹងបានចេះវារាងថាបានច្រើនដែរនឹងកាលនុង

ប៉ុន្តែថាពេលមកដល់ពេលសម័យឥឡូវនឹងភាសាបារាំងអីនឹងខ្ញុំនឹងបានភ្លេចអស់នឹងហើយនឹងចឹងភាសាបារាំងនឹងនោះ។

បើសិនជាភាសាខ្មែរយើងនឹងវិញនឹងអាចនឹងចេះចាំបានសរសេរអីនឹងបានមើលបានអីនឹងចឹងណា!

ក៖ ចាស!

ខ៖
អាចបាន!កាលនៅពីសម័យកាលនៅពេលសម័យពីសង្គមនឹងកាលនឹងភាសាបារាំងនឹងខ្ញុំនឹងអាចនឹងអាននឹងចេះសរសេរអីនឹងបានច្រើនដែរតើ!
ប៉ុន្តែកាលនុងអត់នឹងមានចេះភាសាអង់គ្លេសនោះទេកាលនុងបានចេះត្រឹមតែភាសាបារាំងនឹងកាលនុងណា!ហាស!

ក៖ ចាស!ចឹងភាសាបារាំងនឹងលោកតាអាចឹងចេះសរសេរនឹងចេះអានបានដែរឬទេ?

ខ៖ ចេះសរសេរ
បានខ្លះ២នឹងណា!កាលនៅពេលមុននឹងតែមកដល់ពេលឥឡូវនឹងខ្ញុំនឹងបានភ្លេចវានឹងបានខ្លះៗនឹងទៅហើយព្រោះអីយើងនឹងវាចាស់ហើយវាបានយូរណាស់ទៅហើយណា!

ក៖ លោកតាកាលពីមុននឹងលោកតាបានចូលរៀននៅឯសាលាណាដែរ?

ខ៖ បានរៀននៅក្នុងសាលាបឋមសិក្សា ស្វាយរមៀតនៅក្នុងឃុំ ខ្ពង់រាច
នឹងកាលនឹងគេបានហៅថាសាលា
អូសណៃកនៅឯខេត្តព្រៃវែងនឹងកាលនឹងគេបានហៅថាជាសាលាគំរូទៀតនឹងកាលនឹងនុង។
កាលនឹងសាលានឹងអាមេរិកកាំងនឹងគេជាអ្នកដែលបានធ្វើអោយនឹង!

ក៖ អូ!...

ខ៖ នឹងហើយ!ពេលនឹងគ្រូអីនឹងកាលនឹងសុទ្ធតែនឹងយកពីកំពង់កន្ទួតនោះទេ!

ក៖ នៅឯព្រៃវែងនឹងតែម្តង?

ខ៖ បាទ! សាលានឹងមួយខេត្តនឹងមាន១ សាលាគំរូនឹងណា!មួយខេត្តនឹងមាន១ៗ។
ចឹងនៅក្នុងខេត្តព្រៃវែងនឹងសាលាដែលខ្ញុំនឹងបានរៀននឹងវាជាសាលាគំរូ ។

ក៖ ចាស!

ខ៖ បាទ!

កៈ
ចឹងកាលនុងពេលដែលលោកតាបានរៀននឹងកាលនឹងលោកតាមានមិត្តភក្តិស្និតស្នាលដែរឬទេ?

ខៈ បាទ!មានមិត្តភក្តិស្និតស្នាល
មានមិត្តភក្តិនឹងស្និតស្នាលនឹងកាលនឹងនុងចឹង!ហើយពេលដែលយើងនឹងបានបែកចឹងហើយនឹង!ពេលដេលស្រុកនឹងវាបានកើតជាសង្គ្រាមអីនឹងចឹងហើយនឹងពេលដែលបានមកបែកសង្គ្រាមនឹងចឹងគេនឹងបានរៀបចំនឹងមកវិញនឹងចឹងទៅគេនឹងបានហៅរកខ្ញុំនឹងទៅធ្វើការងារនឹងជាគ្រូជាអីនឹងចឹងណាគេនឹងបានហៅអីនឹងចឹងទៅណា!កាលនុងពេលដែលថាបានបែកភ្លាមៗនឹង
កាលនុងគេនឹងបានខ្វះខាតគ្រូនោះកាលនុងចឹង!គេនឹងបានមកហៅខ្ញុំនឹងអោយទៅធ្វើជាគ្រូនឹងចឹងទៅកាលនឹងចឹងណា!

កៈ ចាស!!

ខៈ ដល់ចឹងទៅកាលនឹងនុងចឹងខ្ញុំនឹងអត់ទៅធ្វើនោះទេការងារនឹង!

កៈ មិត្តភក្តិរបស់លោកតាកាលនុងគាត់មានឈ្មោះអ្វីគេខ្លះដែរ?

ខៈ
អូ!...ចំពោះមិត្តភក្តិរបស់លោកតាវិញនឹងកាលនឹងគេនឹងមានឈ្មោះច្រើនណាស់នៅសម័យកាលនុង!មានខ្លះទៅបាននៅចាំនឹងចឹង!ខ្លះទៅក៏អត់បាននៅចាំ!

កៈ ចំពោះតែមិត្តភក្តិដែលស្និតស្នាលខ្លាំងជាងគេនឹងតែម្តងនឹងលោកតា?

ខៈ បើសិនជាបានស្និតស្នាលនឹងខ្លាំងជាងគេនឹងមានឈ្មោះថា មានតាមួយនឹងតា ម៉ែន សារី ហើយដល់ពេលឥឡូវនឹងគាត់នឹងអាត្រែតនឹងអស់ទៅហើយ! តាមួយទៀតនឹងមានឈ្មោះថា ហ៊ម គីហ៊ាង នឹងគាត់នឹងសុទ្ធតែអាត្រែតនឹងអស់ទៅហើយហោស!
សុទ្ធតែនៅនឹងចឹង!បានចាំនឹងតែប៉ុណ្ណឹងហើយមាននៅប៉ុន្មាននាក់ទៀតនឹងបានស្លាប់ទៅនឹងខ្លះចឹង
ប៉ុន្តែនឹងខ្ញុំនឹងវាបាននឹងភ្លេចឈ្មោះនឹងហើយព្រោះអីនឹងបានមកនេះចឹងណា!ចឹងហើយនឹងខ្ញុំនឹងបានភ្លេចឈ្មោះនឹងចឹងបាត់ទៅ!

កៈ ចាស!

ខ៖ នឹងហើយ!

ក៖
ចឹងមកដល់ពេលឥឡូវនឹងគាត់នឹងបានទាក់ទងអីនឹងជាមួយនឹងលោកតានឹងដែរឬទេមកដល់ឥឡូវនឹងលោកតា?

ខ៖
អឺ!...ពេលដែលខ្ញុំនឹងបានទៅស្រុកអីនឹងបានម្តងៗនឹងចឹងគាត់នឹងបានចេះតែនឹងធ្វើការសួរនាំអីនឹងសុខទុក្ខអីនឹងចឹងដែរចឹងណា!ហេសៗៗ!

ក៖ ចាស!

ខ៖ ហេសៗ!

ក៖
ចាស!លោកតារឿងកាលពីលោកតានៅកាលពីក្មេងនឹងតើលោកតាមានបាននៅចាំរឿងអីគេខ្លះដែរ?

ខ៖ បាទ!

ក៖
រឿងកាលពីលោកតានៅពីក្មេងៗនឹងនៅពេលជាមួយនឹងមិត្តភក្តិជិតស្និតរបស់លោកតានឹងតើលោកតាមានបាននៅចាំអ្វីគេខ្លះដែរជាមួយនឹងពួកគាត់?

ខ៖
អូ!...កាលនឹងលោកតានឹងបាននៅជាមិត្តភក្តិស្និតស្នាលនឹងគាត់នឹងកាលនឹងតាចាំកាលពីមុននឹងនៅពេលនៅក្នុងវ័យសិក្សានឹងទាំងអស់នឹងគ្នានឹងកាលនឹងនុងពេលនឹងមិត្តភក្តិរបស់ខ្ញុំនឹងកាលនឹងខ្ញុំនឹងវាបានរៀននៅខ្សោយនឹងជាងគេនឹងចំណែកឯមិត្តភក្តិរបស់ខ្ញុំនឹងវិញនឹងកាលនឹងគេនឹងបានរៀនពូកែៗជាខ្ញុំនឹងកាលនុង!
ព្រោះអីនៅសម័យកាលនឹងគេនឹងបានមានដូចថាសម័យកាលនឹងមានអ្នកខ្លះចឹងទៅបានធ្លាក់ឌីផ្លូមអីនឹងចឹងខ្លះចឹងទៅ ហើយមានឌីផ្លូមអីនឹងខ្លះ!
ហើយបើសិនជាបាក់ឌុមនឹងកាលនឹងដូចជាមានតែម្នាក់នឹងតែ២នាក់នឹងនោះទេកាលនុង!កាលនុងណា!ពេលនឹងវាបានច្រើនតែឌីប្លូមនឹងនោះទេ!ចឹងពេលនឹងមានអ្នកខ្លះទៅបានធ្លាក់ឌីប្លូមនឹងខ្លះទៅហើយនឹងចឹងមានអ្នកខ្លះចឹងទៅបានជាប់ឌីប្លូមនឹងចឹងខ្លះទៅចំណែកឯខ្ញុំនឹងវិញ

នឹងកាលនឹងខ្ញុំនឹងវាបានរៀននឹងនៅរាងថាអន់នឹងជាងគេនឹងកាលនុង!ចឹងណា!ហើយចឹងខ្ញុំនឹងចេះតែបានបែកមុខវិជ្ជានឹងចឹងកាលនឹងចេះតែរករៀនមុនវិជ្ជាផ្សេងផ្សេងៗអីនឹងចឹងកាលនឹងនុងណាកាលនឹងនុងចឹងហេសៗ!ចឹងទៅ។

ក៖
ចឹងលោកតា!ហើយចឹងកាលនឹងលោកតាមានបានចូលចិត្តនឹងលេងអីនឹងជាមួយនឹងមិត្តភក្តិដែរកាលនៅសម័យនឹង?

ខ៖
ហេស!...កាលនៅក្នុងសម័យខ្ញុំនឹងដូចជាមិនបាននឹងចូលចិត្តនឹងលេងអីនឹងអីដែរនោះទេហេសៗ!

ក៖ ចាស!លោកតាចឹងលោកតាជាអ្នកដែលឡធ្វើស្រែត្រូវអត់លោកតាកាលពីសម័យមុខ?

ខ៖ បាទ?

ក៖ លោកតាធ្លាប់បានធ្វើស្រែត្រូវអត់?

ខ៖ បាទ!ៗកាលពីមុននឹងខ្ញុំធ្លាប់បានធ្វើស្រែ!

ក៖ ចឹងអឺ...លោកតាការងារអ្វីគេខ្លះនៅក្នុងជីវិតរបស់លោកតាដែរលោកតាបានធ្វើកន្លងមក?

ខ៖
ខ្ញុំបានធ្វើចាប់បីដៃគ្នានឹងបានជាប្តីនឹងប្រពន្ធនឹងមកនឹងខ្ញុំនឹងបានធ្វើការងារស្រែនឹងផងហើយនឹងមុខរបររបស់ខ្ញុំនឹងមួយទៀតនឹងខ្ញុំនឹងបានធ្វើជាជាងដេរ!
បានដេរខោអាវនឹងបានដេរសំលៀកបំពាក់អីនឹងទៀតចឹងទៅណា!
បានកាត់ខោអាវនឹងសំលៀកបំពាក់អីនឹងចឹងទៅណា!បាទ!

ក៖ បែបសម័យបែបបុរាណឬក៏អ្វីដែរទៅលោកតា?

ខ៖ បាទ!

ក៖ ទាំងអស់?

ខ៖ បែបសម័យនឹងខ្លះបែបបុរាណនឹងខ្លះទៅកាលនុងបាទ!ព្រោះអីយើងនឹងបុរាណ។

ក៖ ចាស!លោកតានៅពីសម័យកាលនុងលោកតាបានចេះរៀនជំនាញដែរនឹងពីណាមកដែរ?

ខ៖
រៀនជំនាញដេរនឹងកាលនឹងមកពីមេជាងធំនឹងកាលនឹងគាត់នឹងបាននៅឯខាងមេមុតឯនោះ។

ក៖
ចាស!ហើយចឹងលោកតាបានធ្វើការជំនាក់ស្រុកនឹងទៅដល់មេមុតនឹងដើម្បីអី!រៀនចឹងណា?

ខ៖ បាទ!ដើម្បីរៀនសិក្សានឹងណាដើម្បីនឹងស្វែងរកមុខវិជ្ជានឹងបានផ្ទាល់ខ្លួននឹងកាលនុង!

ក៖ ចាស!

ខ៖ បានដេរនឹងកាត់សំលៀកបំពាក់នឹងណា!

ក៖
ចាស!ចុះចំពោះជំនាញ់ខាងកាត់ដេរនឹងលោកតាបានរៀនបានជំនាញ់នឹងបានប៉ុន្មានឆ្នាំដែរនឹងហើយលោកតាអាចនឹងកាត់ដេរនឹងបាន?

ខ៖
ហឺ!កាលនឹងខ្ញុំនឹងបានរៀននឹងយូរបាន៣ទៅ៤ឆ្នាំអីនឹងដែរនឹងនៅសម័យកាលនុង!បាន៥ឆ្នាំទៅ៦ឆ្នាំដែរទៀតរហូរទាល់តែពេលនុងខ្ញុំនឹងបានដើរទៅខ្ញុំគេ( អ្នកបំរើ)នឹងទៀតនឹងហ៎។

ក៖
អូ!ចឹងកាលនឹងលោកតាបានរៀននឹងបានយូរនឹងហើយចឹងកាលនឹងលោកតាចេះដេរអីនឹងបានអស់រលីងអីនឹងតែម្តង?

ខ៖ បាទ!បានចេះដេរអីនឹងបាន!

ក៖
ការនឹងហេតុអ្វីបានជាលោកតារៀនបានយូរម៉េចគ្រាន់តែរៀននឹងឬក៏លោកតានៅរៀនផ្នែកច្នៃម៉ូតអីនឹងទៀត?

ខ៖
បើសិនជាគ្រាន់តែរៀននឹងវាមិនទៅជាយូរអីនឹងបានប៉ុន្មាននោះទេកាលនុងតែកាលនឹងខ្ញុំនឹងបានទៅខ្ញុំគេនឹងកាលនឹងបានទៅស៊ីឈ្នួលគេនឹងកាលនឹងនុង។
យើងនឹងបានរៀនបាន២ទៅ៣ឆ្នាំនឹងបានចេះនឹងចឹងកាលនឹងយើងនឹងក៏បានដើរទៅស៊ីឈ្នួល

នឹងអោយដល់គេនឹងកាលនឹងបានប្រាប់ខែនឹងចឹងបាន៣០០នឹងកាលនឹងចឹងកាលនឹងបាន៣០០នឹងបានស៊ី...

ក៖ បានថ្លៃ!

ខ៖ កាលនឹងបានប្រាប់៣០០នឹងកាលនឹងបានមាសនឹងបាន១ជី...កាលនឹងបើសិនជាបាន៣០០នឹងបានមាសនឹងបាន១ជីដែលនឹងកាលនៅពេលនុង!មាសពេលនឹងបានស្មើនឹងតំលៃលុយនឹង១ជីនៅកាលនុង។

ក៖ ចឹងបានថ្លៃណាស់នឹង!

ខ៖ បាន៣០០នឹងកាលនឹងបាន១ជី!

ក៖បាន៣០០នឹងណា!ចាស!

ខ៖ ចឹង៣០០កាលនឹងបានមាសនឹង១ជី!មួយខែនឹងបាន៣០០នឹងបានរហូតដល់៤០០នៅក្នុងមួយខែនឹងរហូតបានឡើងនឹងដល់នៅក្នុងមួយខែនឹងបានដល់១០០០ ដល់១៦០០នឹងបាទ!

ក៖ អូ!...

ខ៖ ចឹងកាលនឹងនុងខ្ញុំនឹងបានលែងនឹងចឹង!ពេលនឹងខ្ញុំនឹងលែងនឹងកាលនឹងដោយសារតែខ្ញុំនឹងបានឡើងប្រាក់ខែនឹងបានដល់១៦០០នឹងចឹងទៅកាលនឹងខ្ញុំនឹងក៏បានលែងធ្វើចឹងទៅ!

ក៖ ហឺ!...

ខ៖ ចឹងកាលនឹងខ្ញុំនឹងបានដើរឈរជាមេកានឹងគេវិញម្តង។

ក៖ ចាស!

ខ៖ ឈរធ្វើមេការនឹងបានចាំនឹងតែទទួលភ្ញៀវអីនឹងចឹងទៅពេលដែលភ្ញៀវនឹងបានមកនឹងចាំទទួលភ្ញៀវអីនឹងចឹងទៅហើយដល់ចឹងពេលដែលមានភ្ញៀវនឹងគេមករើសអីនឹងចឹងទៅយើងនឹងឈរអោយជាងនឹងគេនឹងវាស់ដេរអីនឹងចឹងទៅណា!

កៈ ចាស!

ខៈ
ចឹងកាលនឹងតានឹងបានទទួលជាមេកានឹងគេនឹងចឹងទៅកាលនឹង!ហើយនឹងចឹងកាលនឹងពេលដែលបានដល់ប្រាក់ខែនឹងដល់១៦០០អីនឹងចឹងបានហើយនឹងចឹងកាលនឹងតានឹងបានទៅធ្វើជាមេកានឹងក៏បានប្រាក់ខែនឹងដល់១៦០០នឹងដែរចឹងហើយកាលនឹងនុង១៦០០នឹងកាលសម័យនឹងកាលនឹង១៦០០នឹងវាមិនធម្មតានោះទេនៅសម័យកាលនុងណា!

កៈ ច្រើន!លោកតាឥឡូវនឹងរកប្រៀបមិនបាននោះទេ!

ខៈ
កាលនៅសម័យនឹងពេលដែលគ្រូបង្រៀនអីនឹងបានតែ១៨០០នោះទេកាលនឹងគ្រូបង្រៀននឹងកាលនឹងនុងគ្រូបឋមនឹង!

កៈ នឹងនៅក្នុង១ឆ្នាំ?

ខៈ គ្រូបឋមនឹង!តែ១៨០០នឹងនោះទេណា!

កៈ ចុះនឹងនៅក្នុង១ឆ្នាំមែនលោកតា?

ខៈ នៅក្នុង១ខែទេអានឹង!

កៈ ក្នុង១ខែ!

ខៈ នឹង!

កៈ កាលនុង១៨០០ដុល្លាមែនតា?

ខៈ ១៨០០លុយខ្មែរនឹង។

កៈ អូ!...

ខៈ ហេសៗៗៗ!មិនមែន១៨០០នឹងលុយដុល្លានឹងនោះទេណា!

កៈ ហេសៗ!ចុះកាលនឹងវាបានថ្លៃកាលនឹងលុយបានថ្លៃ។

ខៈ បាទ!
នៅពេលនឹងខាងអនុវិទ្យាល័យអីនឹងអានឹងបានបានពី៣០០០អីនឹងទៅ៤០០០អីនឹងចឹងទៅ

ណា
ចឹងពេលនឹងកំរិតអាំស៊ីទ័រអីនឹងបាន៥០០០ទៅ៥០០០នឹងលុយខ្មែរយើងនឹងណាកាលនុង។ចឹងកាលនឹងនុងលុយនឹងវាមានតំលៃណាកាលនុងលុយថ្លៃ
លុយ៣០០នឹងកាលនឹងបានមាសនឹងបាន១ជីនឹងាណាកាលនុងនោះ!មិនមែនដូចជាពេលនឹងនេះសម័យនេះនឹង១ជីនឹងមានត្រូវការលុយប៉ុន្មាន!

ក៖ អូ!..ឥឡូវនឹងថ្លៃណាស់ឥឡូវនឹងលុយចុះថោកមាសនឹងថ្លៃយ៉ាងនេះ។

ខ៖ បាទ!

ក៖
អូ!លោកតាចឹងកាលនឹងលោកតាបានរៀនផ្នែកកាត់ដេរនឹងកាលនឹងលោកតាបានស្រលាញ់នឹងតែម្ដងឬក៏យ៉ាងម៉េចដែរ?

ខ៖ កាលនឹងខ្ញុំនឹងបានស្រលាញ់នឹងផ្នែកខាងនឹង!

ក៖ ស្រលាញ់ផ្នែកនឹង!ចឹង!

ខ៖ បាទ!

ក៖
ចឹងចំពោះបំណងប្រាថ្នាតាំងពីតូចនឹងមកនឹងលោកតាបានធ្លាប់នឹងបានស្រមៃថានឹងចង់ធ្វើជាអ្នកកាត់ដេរអីនឹងតែម្ដងនឹងហ៎?

ខ៖ នឹងហើយកាលនឹងប្រាថ្នានឹងចង់ធ្វើជាអ្នកកាត់ដេរខោអាវនឹង។

ក៖ ចាស!ចឹងបានសំរេចដូចសេចក្ដីប្រាថ្នា!

ខ៖
បាទ!ចឹងកាលនុងដល់ពេលស្រុកនឹងចឹងកាលនឹង!..ដល់ពេលស្រុកយើងនឹងកើតចឹងទៅកាលនឹងខ្ញុំនឹងបានបើកនឹងបានតែ១ឆ្នាំនឹងគត់នឹងកាលនឹងនុងព្រោះអីចឹងកាលនឹងយើងនឹងក៏បានខាននឹងដេរទៅហើយមកដល់ពេលឥឡូវនឹងខ្ញុំនឹងបានចាស់អីនឹងចឹងទៅក៏បានខាននឹងដេរនឹងមករហូតនឹងចឹងទៅណា!

ក៖
លោកតានៅសម័យការនឹងកាលនឹងលោកតាបានទៅស៊ីឈ្នួលគេនឹងកាលនឹងនៅរោងចក្រឬក៏នៅឯណាដែរកាលនឹង?

ខ៖
អត់នោះទេ!កាលនឹងយើងនឹងបានទៅស៊ីឈ្នួលអោយគេនឹងកាលនឹងនៅក្នុងខាងបែកចាននៅខាងកំពង់ស្ពឺអីនឹងកាលនឹងខ្ញុំនឹងបានធ្វើនឹងទាំងអស់នឹងកាលនុងនោះ!

ក៖
ហាក់ចឹងកាលនឹងមានន័យថាពេលនឹងលោកតាបានទៅដេរនឹងនៅតាមផ្ទះរបស់គេយកម៉ាស៊ីននឹងចឹងទៅបានដេរហើយអីនឹងចឹងបានយកទៅអោយគេនៅតាមផ្ទះ?

ខ៖
ហេស!កាលនឹងខ្ញុំនឹងបានទៅស៊ីឈ្នួលអោយគេនឹងកាលនឹងគឺខ្ញុំនឹងបានទៅដេរនៅឯផ្ទះគេនឹងតែម្តងព្រោះអីពេលនឹងគេនឹងមានម៉ាស៊ីនអោយសំរាប់នឹងយើងនឹងដេរអោយគេនឹងតែម្តងនឹងកាលនឹងគេនឹងជាជាងនឹងចឹងទៅហើយយើងនឹងកាលនឹងជាអ្នកដែលជួយគេនឹងបានដេរអីចឹងកាលនឹងដល់ពេលហើយទៅដេរបានប៉ុន្មានអីនឹងយើងនឹងរាប់អោយគេចឹងទៅណា!

ក៖ ចាស!

ខ៖ អត់នឹងមានរោងចក្រអីនឹងចឹងនោះទេកាលនឹងនៅក្នុងសម័យកាលពីដើមនឹងនោះ។

ក៖ ចាស! ចុះដល់ពេលក្រោយមកទៀតនឹងលោកតាបានបើកដោយខ្លួនឯងនឹង...

ខ៖
កាលនឹងបានបើកនឹងដោយខ្លួនឯងនឹងកាលនឹងបានបន្តិចបន្តួចណាស់កាលនុងចឹងព្រោះអីបានតែ១ឆ្នាំនឹងចឹងកាលនឹងនុងចឹងបានជាពេលនឹងស្រុកយើងនឹងវាចឹងទៅបានជាយើងនឹងបិទហើយនឹងរត់ទៅគ្រាតតគ្រាយអីនឹងចឹងអស់ទៅណា!

ក៖ ហឺ!...

ខ៖
នឹងហើយកាលនឹង!យើងនឹងបានរត់នឹងគេចរកតែនឹងអាយុនឹងបានរាងខ្លួននឹងវិញចឹងទៅណា។

កៈ ចាសត្រូវហើយ!

ខៈ
នឹងហើយចឹងតានឹងទំរាំតែនឹងបានរស់មកដល់ពេលសព្វថ្ងៃនឹងវិញនឹងកាលនឹងវាមិនស្រួល
នោះទេ។

កៈ
ចាស!លោកតាដល់ពេលចឹងតើលោកតាមានបាននៅចង់ចាំរឿងអីខ្លះដែរនៅពេលសម័យរប
ស់លោកតាកាលពីមុន?

ខៈ
ចង់ចាំនឹងកាលនឹងចង់ចាំពេលដែលលោកតានឹងបានលំបិននឹងលំបាកនឹងកាលនឹងនុងតានឹង
បានចង់នឹងចាំថាពេលនឹងវានឹងវាវេទនានឹងកាលនឹងនុងហោសៗ!

កៈ ចាស!

ខៈ នឹងហើយ!

កៈ
ចឹងលោកតាកាលពីក្មេងនឹងមកនឹងតើលោកតាមានជីវិតនឹងបានប្រែប្រួលអីគេនឹងបានខ្លះដែរ
?

ខៈ
វាជីវិតនឹងប្រែលប្រួលនឹងវាចេះតែនឹងបានសព្វបែបនឹងសព្វយ៉ាងនឹងដែរនឹងហើយកាលនៅក្នុ
ងពេលសម័យនោះមក
ព្រោះអីតានឹងជាអ្នកដែលបានធ្វើស្រែនឹងកាលនឹងគ្មាននឹងបានធ្វើជាចំការអីនឹងផង!មកដល់
យើងនឹងបានប្រឹងសិក្សាអីនឹងចឹងទៅ!ហើយអោយបានចេះដឹងអីនឹងចឹងទៅចឹងយើងនឹងក៏បា
នចេះនឹងដឹងបានបន្តិចបន្តួចអីនឹងចឹងទៅហើយចឹងយើងនឹងក៏បានចេះនឹងបានខំប្រឹងនឹងស្វា
សស្វែងនឹងអីនឹងចឹងទៅ!រកមុខវិជ្ជាអីនឹងបានរៀងផ្ទាល់ៗនឹងខ្លួនអីនឹងចឹងទៅណា!

កៈ ចាស!

ខៈចឹងហើយ!ដល់ចឹងហើយនឹងបានយើងនឹងបានចឹងដល់មកពេលឥឡូវនឹងមកនឹងណា!

កៈ ចាសលោកតា! ហើយចឹងមកដល់ពេលក្នុងសម័យពេលឥឡូវនេះនឹងតើលោកតាមានបានចូលចិត្តមុខម្ហូបអីគេដែរតាំងពីក្មេងនឹងមកដល់ពេលឥឡូវនឹង?

ខៈ មុខម្ហូប?

កៈ ចាស!

ខៈ អូ!ចំពោះមុខម្ហូបនឹងខ្ញុំនឹងបានចូលចិត្ត តែហូបត្រីនឹងគេនឹងទេ!ហោស!

កៈ ហោស!

ខៈ តែចំពោះកាលពីមុននឹងខ្ញុំនឹងបានហូបសាច់អីនឹងដែរតែដល់ពេលក្រោយមកនឹងវាអត់នឹងបានហ៊ានទេសាច់អីនឹងអត់នោះទេឥឡូវនឹងបានហូបតែត្រីនោះទេព្រោះអីដំណើររបស់យើងនឹងវាចាស់ណាស់ទៅហើយចឹងទៅ!ហើយចឹងខ្ញុំនឹងមិនបាននឹងសូវជាចូលចិត្តសាច់នោះទេ។

កៈ ចាសលោកតា!

ខៈ នឹហើយ!ចឹងខ្ញុំនឹងបានតែហូបត្រីនោះទេនៅពេលឥឡូវនឹង!

កៈ ចាសលោកតា!

ខៈ បាទ!

កៈ ចឹងមុខម្ហូបអីគេក៏បានដែរអោយតែមានត្រី?

ខៈ បាទ!ៗ អោយតែមានត្រីដូចជាមានត្រីអាំង ត្រីងៀត ត្រីស្ងោរ ចឹងអោយតែត្រី។

កៈ ចុះចំពោះល្បែងវិញ ដែលជាល្បែងលេងកាលពីនៅក្មេងៗនឹងតើលោកតាចូលចិត្តនឹងលេងល្បែងលេងអីគេខ្លះដែរ?

ខៈ ខ្ញុំនឹងដូចជាអត់មានចំណូលចូលចិត្តអីនឹងសោះដូចជាអត់នឹងចំណូលខាងល្បែងអីនឹងលេងអីនឹង។

កៈ ដូចជាមានល្បែងលេងបាល់បោះបាល់ លេងឃ្លៅ បោះអង្គុញអី?

ខ៖
អត់ទេអាល្បែងអីនឹងខ្ញុំនឹងអត់ចូលចិត្តនឹងលេងនោះទេបើសិនជាលេងវិញក៏បានលេងអីនឹងបានតិចតួចអីនឹងចឹងដែរទៅណា!ហេសៗៗ!

ក៖ អូ!...

ខ៖
អានឹងដូចថាពេលដែលបានហាត់ប្រាណអីនឹងបានលេងអីនឹងបានបន្តិចបន្តួចអីនឹងចឹងទៅណា!ដូចជាលេងទាល់បាល់អីនឹងបានលេងចឹងតែបន្តិចបន្តួចនោះទេព្រោះអីខ្ញុំនឹងវាអត់នឹងចេះអីជាអ្នកដែលថានឹងលេងអីនឹងគេនោះទេនៅកាលនឹងនោះណា!

ក៖ ចាស!

ខ៖ បាទ!

ក៖
ចុះសំរាប់បទចម្រៀងនឹងវិញតាំងពីកាលពីក្មេងនឹងវិញនឹងកាលនឹងនុងមកនឹងដល់ពេលឥឡូវនឹងលោកតាចូលចិត្តស្តាប់បទចម្រៀងដែរឬទេ?

ខ៖
ខ្ញុំនឹង!អា!ថាវាបានចូលចិត្តនឹងស្តាប់ដែរនឹងណាតែគ្រាន់តែថាអត់នឹងបានចង់ចាំអីនឹងនោះទេព្រោះអីកាលនឹងវាអត់បានចាំនោះទេហេសៗៗ!

ក៖ ហឺ!...

ខ៖ ចូលចិត្តនឹងចូលចិត្តតែពីរឿងថារៀនធម៌អីនឹងអានឹងគឺចូលចិត្តនឹងតែម្តង
គឺបានចូលចិត្តនឹងរហូតនឹងមកដល់ពេលឥឡូវនឹងណា!

ក៖ ចឹង!

ខ៖ ចូលចិត្តខាងធម៌!

ក៖ ចាស!

ខ៖ ចូលចិត្តស្តាប់ធម៌អីនឹងចឹងទៅណា!

ក៖
ចាស!ចំពោះឧបករណ៍ភ្លេងនឹងវិញនឹងលោកតាតើបងប្អូននឹងរបស់លោកតានឹងគាត់នឹងមានបានចេះលេងឧបករណ៍ភ្លេងដែរឬទេលោកតា?

ខ៖ អត់មានទេហេស!ៗ
គ្មាននរណាគេដែលបានចេះខាងឧបករណ៍ខាងភ្លេងអីនឹងអត់មាននោះទេ!អត់បានមាននោះទេ។

ក៖
អូ!...ចាសលោកតា!ចំពោះផ្ទះរបស់លោកតាវិញតើតាំងពីក្មេងនឹងមកដល់ពេលឥឡូវនឹងតើផ្ទះរបស់លោកតាមានលក្ខណៈយ៉ាងម៉េចបែបណាដែរ?

ខ៖
អូ!...កាលនៅក្នុងសម័យកាលពីក្មេងវិញនឹងកាលនុងដូចថាពេលនឹងផ្ទះនឹងជាផ្ទះរបស់អ្នកស្រុកស្រែនឹងកាលនុងចឹងវាជាផ្ទះឈើនឹងនោះទេកាលនឹងនុងចឹងហើយបានធ្វើការផ្លាស់ប្តូរនឹងទៅជាប៉ុន្មានជំនាន់នឹងដែរហើយនឹងចឹង។បានប៉ុន្មានលើនឹងបានប៉ុន្មានសារហើយនឹងចឹង!មកដល់នៅក្នុងពេលសម័យនឹងចឹងក៏ផ្ទះរបស់ខ្ញុំនឹងសព្វថ្ងៃនឹងក៏ជាផ្ទះឈើអីនឹងដែរ!អើយ!តែវានឹងគ្រាន់តែថាវានឹងសមរម្យនឹងវានឹងមិនទៅរង្គើរអីនឹងបានអាក្រក់អាក្រោកអីនឹងទេណា។

ក៖ ចាស!

ខ៖ នឹងហើយ!

ក៖ ហើយអឺ!...ការសាងសងផ្ទះនឹងចឹងកាលនឹងនុងលោកតាបានជួលគេឬក៏ធ្វើដោយខ្លួនឯង?

ខ៖
បាទ!ការសាងសងផ្ទះនឹងគឺខ្ញុំជួលគេនឹងនោះទេ!ហេស!ៗខ្ញុំនឹងបានទៅជួលជាងគេនឹងមកធ្វើនោះទេបាទ!ហេសៗ!

ក៖ ចុះចំណែកឯសំភារៈអីនៅក្នុងផ្ទះនឹងលោកតាបានទៅជួលគេឬក៏យ៉ាងណាដែរ?

ខ៖
អូ!...ចំពោះសំភារៈនៅក្នុងផ្ទះវិញនឹងខ្ញុំនឹងបានទៅទិញគេនឹងនោះទេកាលនឹងនុងបាទ!កាលនឹងមានខ្លះទៅកូនចៅនឹងគេនឹងបានទៅទិញគេអីនឹងខ្លះទៅចឹង!ដល់ពេលឥឡូវនឹងមានសំភារៈនឹងបានប្រើប្រាស់អីនឹងបានសព្វគ្រាប់នឹងបែបយ៉ាងនឹងគឺខ្ញុំនឹងពេលនឹងវានឹងមិនទៅអួតមិន

ទៅអាងអីនោះទេមកដល់ពេលឥឡូវនឹងខ្ញុំនឹងវាមិនទៅខ្វះអីនោះទេ!ឥឡូវសំភារៈប្រើប្រាស់នឹង។

កៈ
ចាស!ហើយចឹងកាលនោះមានឈើអីនឹងតើលោកតាបានប្រើប្រាស់ឈើអ្វីដែរដើម្បីនឹងយកមកសាងសងផ្ទះ?

ខៈ
កាលនឹងនុងខ្ញុំនឹងបានយកឈើនឹងល្អណាស់ដើម្បីនឹងយកមកដើម្បីនឹងសាងសងផ្ទះនឹងមានឈើស្រឡៅ ឈើកកោះ នឹងមានឈើ កក្រុំនឹងបាទ!សំរាប់នឹងធ្វើផ្ទះនឹងណា!

កៈ ចាស!

ខៈ និយាយចឹងមានប្រើឈើទាលខ្លះដែរមិនថាវាធ្វើនឹងសុទ្ធទាំងអស់នឹងនោះទេ!

កៈ ចាស!នឹងហើយលោកតា។

ខៈ
ចំពោះដល់ពេលឥឡូវនឹងផ្ទះគេនឹងលែងនឹងធ្វើជាឈើនឹងទៅហើយគេបានធ្វើនឹងដែកនឹងណា!

កៈ ហឺ!ចាស!ចឹងផ្ទះរបស់លោកតានឹងសព្វថ្ងៃនឹងគឺមានលាយថ្មហ៎លោកតា?

ខៈ អត់នោះទេធ្វើដោយឈើនោះទេ!

កៈ ឈើទាំងអស់តែម្តង?

ខៈ បាទ!ធ្វើអំពីឈើនឹងទាំងអស់តែម្តងប៉ុន្តែគ្រាន់តែថាដូចជា យ៉ាបៗ(
ដំបូលផ្ទះដែលគេបានធ្វើសំរាប់នឹងតមកខាងមុនផ្ទះអោយមានសភាពលានចេញមកខាងក្រៅផ្ទះ)នឹងយើងនឹងបានតជាដែកអីនឹងខ្លះចឹងទៅណា។

កៈ
ចាស!ៗចឹងលោកតាដូចជាលោកតាសព្វថ្ងៃនឹងនេះនឹងលោកតាជាលោកតាអាចារ្យវត្តនៅក្នុងវត្តព្រះពុទ្ធមានបុណ្យនឹងតែម្តង?

ខៈ បាទ!

ក៖ នៅនឹងទីវត្តព្រះពុទ្ធមានបុណ្យនឹងតែម្តង?

ខ៖ បាទខ្ញុំនឹងជាតាអាចារ្យនោះក្នុងវត្តនឹងតែម្តង។

ក៖ មូលហេតុអ្វីបានជានាំអោយលោកតាបានផ្លាស់ប្តូរមុខរបរ?

ខ៖
មូលហេតុដែលបានមកផ្លាស់ប្តូរជាតាអាចារ្យវត្តនឹងដោយសារតែមានបងដែលគាត់ធ្វើជាសគ្រាចវត្ត(សម្តេចសង្ឃជាន់ខ្ពស់ដែលមានឋានៈខ្ពស់ជាងគេនៅក្នុងវត្ត)នៅឯទីនេះនឹងតែម្តង!ដល់ចឹងទៅពេលដែលគាត់នឹងចាស់ជរានឹងគាត់នឹងអត់មានកូនមានចៅអីនឹងចឹងទៅគាត់នឹងក៏បានអោយខ្ញុំនឹងមកជួយមើលការងារនៅវត្តនឹងមានមើលថែរក្សាជំងឺនឹងទៅព្រោះអីលោកនឹងចាស់ណាស់ហើយនឹងចឹងណា។

ក៖ ចាស!

ខ៖
នឹងចឹងមានទឹកក្តៅនឹងទឹកត្រជាក់អីនឹងចឹងទៅមានចង្ហាន់អីនឹងចឹង!មកដល់ពេលឥឡូវនឹងលោកក៏បានសុគតនឹងចឹងទៅ!ហើយចឹងខ្ញុំនឹងក៏បាននៅចាំនៅនឹងវត្តនឹងមករហូតនឹងចឹងទៅ!បាទចឹងខ្ញុំនឹងក៏បានមកធ្វើជាអាចារ្យវត្តនឹងនៅប្រចាំនឹងនៅឯទីនេះនឹងតែម្តងចឹងទៅណា!

ក៖ ចាស!

ខ៖ បាទ!

ក៖
ចាស!លោកតាចឹងលោកតាមានការជួបនឹងកាលនឹងលំបាកអីគេខ្លះដែរក្នុងការធ្វើអាចារ្យនឹង?

ខ៖ ហឺស!
ឥឡូវនឹងនៅក្នុងវត្តនឹងខ្ញុំនឹងបានធ្វើជាអាចារ្យវត្តនឹងបានគ្រាប់គ្រងនៅឯក្នុងវត្តនឹងវាកើតការលំបាកនឹងវាចេះនឹងមានដែលនឹងព្រោះអីយើងនឹងវាបានជាចាស់នឹងជរាហើយចឹងទៅនឹងនៅក្នុងការបំរើបំរើសដល់លោកនឹងវាមើលទៅនឹងវារាងថាលំបាកអីនឹងចឹងដែរនឹងព្រោះអីឥឡូវនឹងខ្ញុំនឹងវាដូចថាបានចាស់នឹងជាងមុនចឹង!វាមិនបានដូចជាពេលដែលយើងនឹងបាននៅកាលពីក្មេងនឹងយើងនឹងបានរាងថាបានរហ័សនឹងរហួននឹងចឹងដើម្បីនឹងជួយចឹងមានការងារវត្តនឹងមានដូចជាការបោសជ្រះអីនឹងនៅក្នុងវត្តនឹងចឹងតែដល់ពេលឥឡូវនឹងវាបានខ្លះទៅមិនបានខ្លះអីនឹងចឹងទៅ!មើលដូចជានេះអីនឹងគេនឹងបានជួយនោះទេ!

ក៖ ហឺ!...

ខ៖
គ្រាន់តែពេលព្រឹកឡើងនឹងត្រូវរៀបចំបំរើដល់លោកនឹងចឹងមានទឹកក្ដៅនឹងទឹកត្រជាក់នឹងចឹងទេ!សំរាប់ឯការងារណាដែលថាវារាងធ្ងន់ៗអីនឹងវាមិនអាចនឹងធ្វើបាននោះទេបានតែការងារស្រាលៗនឹងនោះទេចឹងណា!បាត!

ក៖
ចឹងលោកតាចំពោះព្រះពុទ្ធសាសនាបានជះឥទ្ធិពលអ្វីគេខ្លះដែរនៅក្នុងជីវិតរបស់លោកតា?

ខ៖ នៅក្នុងជីវិតខ្ញុំចំពោះព្រះពុទ្ធសាសនានឹងវាគ្មាននឹងបានជះឥទ្ធិពលអីនោះទេព្រោះអីថាយើងនឹងជាអ្នកដែលបានកាន់សាសនាព្រះពុទ្ធនឹងនៅក្នុងប្រទេសកម្ពុជាយើងនឹងណា!យើងនឹងបានកាន់តាមសាសនាព្រះពុទ្ធនឹងចឹងណា!ដល់ពេលនឹងពេលដែលយើងនឹងបានកាន់សាសនារបស់ព្រះពុទ្ធនឹងចឹងទៅយើងនឹងក៏ត្រូវបានគោរពតាមវិន័យអីនឹងចឹងមកតាមសាសនាអីនឹងចឹងទៅ!ទៅតាមព្រះឧវាទរបស់ព្រះពុទ្ធយើងនឹងចឹងណា!ហឺ!ចំពោះការលំបាកនឹងវាចេះតែមានអីនឹងចឹងមកដែរនឹងគ្រាន់តែថាពេលដែលយើងនឹងទៅរៀនធម៌អីនឹងវាមិនសូវជាបានចេះនឹងបានចាំអីនឹងនោះទេតែគ្រាន់តែថាពេលដែលនៅកាលពីក្មេងនឹងវានឹងអាចឆាប់ចាំអីនឹងចឹងទៅវាចេះតែមានអីនឹងដែរចឹងណា!ហោស!

ក៖
ចាស!ចាសលោកតា!ចឹងចំពោះក្រុមគ្រួសាររបស់លោកតានឹងទាំងអស់គ្នានឹងគាត់បានកាន់សាសនព្រះពុទ្ធសាសនានឹងទាំងអស់គ្នានឹងចឹង?

ខ៖
បាទ!បានកាន់ព្រះពុទ្ធសាសនានឹងទាំងអស់គ្នានឹងបានកាន់ព្រះពុទ្ធសាសនានឹងទាំងអស់គ្នា។

ក៖ ចុះចំណែកឯប្រពៃណីសាសនាអ្វីគេខ្លះដែរដែរថាក្រុមគ្រួសាររបស់លោកតាបានអនុវត្តន៍?

ខ៖ ហឺៗ!អត់មាននោះទេ!អនុវត្តន៍នឹងទៅតាមសាសនាព្រះពុទ្ធនឹង។

ក៖ អឺ!...ដូចជាកម្មវិធីបុណ្យអីគេដែរគាត់បានធ្វើ?

ខ៖ កម្មវិធីអីនឹងផ្សេងៗនឹងគាត់បានធ្វើតាមព្រះពុទ្ធសាសនា ។

ក៖ ទាំងអស់នឹងតែម្ដងលោកតាណំ?

ខ៖ បាទ!ទៅតាមព្រះពុទ្ធសាសនានឹង។

ក៖ ចាស!មានអ្វីគេខ្លះដែរលោកតាអាប្រាប់បានដែរឬទេថាមានកម្មវិធីបុណ្យអ្វីខ្លះដែរ?

ខ៖
កម្មវិធីបុណ្យព្រះពុទ្ធសាសនារបស់យើងនឹងមានទៅតាមទំនៀមទំលាបនឹងបានមកដល់ពេលសព្វថ្ងៃនេះនឹងមានបុណ្យសង្ឃទាន ទ:ខិណាណុបទាន នឹងមានបុណ្យពិច្ច័យបួន ហើយខ្លះទៅនឹងគេនឹងបានចូលចិត្តធ្វើកម្មវិធីបុណ្យឆានអីនឹងដែលទៅតាមថៃអីនឹងក៏គេនឹងចូលចិត្តធ្វើកម្មវិធីឆាននឹងបាំងស្គរដែរនឹងណា!ដូចថាមានខាងសាសនាព្រះពុទ្ធអីយើងនឹងដូចជាមិនបានសូវជាមាននោះទេ!បុណ្យឆានអីនឹងមានតែមួយៗនោះទេ មានតែបុណ្យសង្ឃទាននឹង បុណ្យ ទ:ខិណានុបទាននឹងបុណ្យបច្ច័យបួន ចឹងទៅបុណ្យចំរើនព្រះជនអីនឹងចឹងទៅណា!ច្រើនតែបុណ្យនឹង។រីឯបុណ្យប្រពៃណីនឹងតាមទំនៀមទំលាបនឹងបានមកទៅតាមការកំណត់ការនឹងមានបុណ្យចូលឆ្នាំ បុណ្យជាតិនឹងណា!

ក៖ ចាស!

ខ៖ មានបុណ្យដាក់បិណ្ឌនឹងណា!នឹងហើយ!

ក៖ មានបុណ្យពិសាខបូជានឹងមានបុណ្យមាឃបូជាទៀត!

ខ៖
នឹងហើយ!ឥឡូវនឹងបានជិតនឹងបានដល់ទៀតនឹងហើយនៅសល់តែ២ថ្ងៃនឹងទៀតនឹងបានជិតដល់បុណ្យ សារវណៈបូជានឹងទៀតទៅហើយ។

ក៖ ចាស!

ខ៖
ចឹងបុណ្យសារវណៈបូជានឹងបាននិយាយអំពីព្រះអង្គនឹងបានចាប់បដិសិន្ធិបានប្រសូតបានត្រាស់ដឹងនឹងបានចាប់កំណើតនឹងបានរហូតនឹងមក!

ក៖
ចាស!ៗចឹងក្រុមគ្រួសាររបស់លោកតាទាំងអស់ពួកគាត់បានធ្វើកម្មវិធីបុណ្យនឹងបានទាំងអស់តែម្តងលោកតា?

ខ៖ គេនឹងបានធ្វើទៅតាមដំណើរនឹង!

ក៖ ទាំងមានបុណ្យឆានមានបុណ្យអីទៀតលោកតា?

ខ៖
នេះទៅតាមចំណង់នឹងចំណូលចិត្តរបស់គេនោះទេតើគេនឹងចង់នឹងធ្វើបុណ្យអីនឹងចឹងទៅគេនឹងបានទៅធ្វើបុណ្យនឹងចឹងទៅណា!បាទ!

ក៖ ចាស!

ខ៖ បាទ!

ក៖
ចាស!លោកតាបុណ្យឆាននឹងម៉េចដែរទៅលោកតាគឺគេនឹងបានធ្វើសំរាប់នឹងឧទិសកុសលអីនឹងសំរាប់ទៅដល់អ្នកដែលបានស្លាប់នឹងចឹងត្រូវដែរឬទេ?

ខ៖ ឧទិសនឹងបានដូចនឹងតែគ្នានឹងហោសៗ!

ក៖
ចឹងតើខុសគ្នានឹងយ៉ាងម៉េចនឹងចឹងទៅលោកតាទាំងរួមមានបុណ្យបច្ច័យបួននឹងមានបុណ្យពិសាបូជា ?

ខ៖ អានឹងគេនឹងបានធ្វើទៅតាមលំដាប់ថ្នាក់នឹងទៅតាមប្រពៃណីរបស់យើងនឹង!

ក៖ អូ! ...ចឹងទៅតាមដែលគេនឹងចង់ធ្វើអីនឹងចឹងទៅណា!

ខ៖ អឺ!នឹងហើយ!អឺ!...មានបុណ្យពិសាបូជានឹងអឺ...មានមាឃបូជានឹងមាន សារហេៈបូជានឹង អានឹងមានកំណត់កាលនឹងអាយុនឹង!

ក៖ នឹងហើយ!

ខ៖ ចំណែកឯបុណ្យ ទខិនិទាន
បុណ្យសង្ឃទានអីនឹងមានបុណ្យចំរើនព្រះជនអីនឹងអានឹងអត់នឹងមានកំណត់កាលនោះទេយើងនឹងចង់ធ្វើវានៅក្នុងថ្ងៃណាអីនឹងចឹងក៏បានដែរចឹងទៅ!ចឹងណា!

ក៖ ទៅតាមពុទ្ធបរិស័ទ។

ខ៖
អឺ!វានឹងអាស្រ័យនឹងយើននឹងមានលុយនឹងធ្វើទៅតាមថ្ងៃណាអីនឹងចឹងទៅតាមដល់ថ្ងៃនុងចឹង

ទៅ!បាទ!

ក៖ ចាស!

ខ៖ នឹងហើយ!

ក៖
ចាសលោកតា!ចឹងនៅក្នុងនាមលោកតាជាលោកតាអាចារ្យភាគច្រើននឹងពុទ្ធបរិស័ទនឹងភាគច្រើនឹងគាត់នឹងបានចូលចិត្តធ្វើកម្មវិធីបុណ្យណាច្រើនជាងគេដែរ?

ខ៖ នឹង!នៅក្នុងពុទ្ធបរិស័ទចំណុះជើងវត្តនឹងច្រើនតែនឹងបានទៅធ្វើបុណ្យបច្ច័យបួនបុណ្យសង្ឃទាននឹងបុណ្យដូចថានឹងមានជាសពអីនឹង៧ថ្ងៃអីនឹងចឹងទៅណា!បុណ្យ៩៩ថ្ងៃអីនឹងអានឹងវាទៅតាមបុណ្យសពនឹងរបស់គេនឹងទេណា!
ចឹងមានតែបុណ្យសង្ឃទាន់នឹងបុណ្យបច្ច័យបួននឹងមានតែបុណ្យនឹង។

ក៖ ចាស!

ខ៖ ចំពោះបុណ្យកឋិនទានវិញនឹងវាមានកំណត់កាលនឹង!

ក៖ ចាស!

ខ៖ នៅក្នុង១ឆ្នាំអីនឹងមានតែមួយដងនោះទេ!
បុណ្យដាក់បិណ្ឌនអីនឹងនៅក្នុង១ឆ្នាំនឹងក៏មានតែម្តងនឹងដែរទេណា!

ក៖ ចាស!

ខ៖នឹងពេលបុណ្យចូលឆ្នាំអីនឹងនៅក្នុងមួយឆ្នាំនឹងមានតែមួយដងនោះទេ!ណាមានអីគេទៀត!ហើស!មានអសារហៈនឹងមានមាឃបូជាអីនឹងសារហៈអីនឹងមានតាមខែ
ចឹងបានកំណត់ខែនឹងថ្ងៃអីនឹងចឹង។

ក៖
ចាស!លោកតា!លោកតានឹងអាចប្រាប់ដល់ខ្ញុំនឹងបានដែររទេថានៅក្នុងជីវិតរបស់លោកតាកាលពីមុននឹងមកដល់ក្នុងពេលសម័យឥឡូវនឹងតើលោកតាមានបានធ្លាប់នឹងបានឆ្លងកាត់ការលំបាកអ្វីគេនឹងខ្លះដែរនៅក្នុងជីវិតរបស់លោកតា?

ខ៖
អូ!..ជីវិតនឹងការរស់នៅនឹងតាំងពីមុននឹងមកដល់ពេលនៅក្នុងសម័យនេះនឹងវានឹងបានឆ្លងនឹង

កាត់នឹងការលំបាកនឹងបានយ៉ាងច្រើនជំនាន់នឹងមកហើយនឹង!វាបានឆ្លងកាត់នឹងបានច្រើនជំនាន់នឹងដែរនឹងតាំងពីនៅក្នុងសម័យជំនាន់សង្គមរាស្រ្តនិយមនឹងនុង!ពេលនឹងសង្គមនឹងបានរស់នៅនឹងបានមួយបែបនឹងចឹងទៅកាលនឹងចឹង!ដល់ពេលនឹងមានសង្គ្រាមអីនឹងបានរស់នៅនឹងបានលំបិននឹងលំបាកចឹងកាលនឹងនុង!អាដូចថាពេលមកនៅកាលសម័យជំនាន់សង្គ្រាមនឹងបានដឹងស្រាប់ទៅហើយនឹងថាគេនឹងបានប្រើយើងនឹង!ចឹងហើយបានមកឆ្លងកាត់ពីសម័យសង្គ្រាមនឹងបានមកនឹងរហូតមកដល់នៅក្នុងសម័យនេះនឹងនៅពីក្នុងកាលជំនាន់៧មករានឹងមកទៀតនឹងចឹងតាំងពីនុងមកដល់ឥឡូវនឹងវានឹងរាងថាធូស្រាលនឹងតាំងពីមុននឹងមកដល់ពេលសម័យឥឡូវនឹងទៅចឹងណា!ហើយចឹងមកដល់ពេលនៅក្នុងសម័យនេះចឹងទៅនឹងថាវានឹងបានរាងថាបានប្រែប្រួលនឹងតិចដែរពីសង្គមរាស្រ្តនិយមនឹងមកហើយនឹងចឹងមានជីវៈភាពនឹងរាងបានធូរធាអីនឹងបានបន្តិច!តាបានធ្លាប់ឆ្លងកាត់នឹងតាវាបានប៉ុន្មានជំនាន់នឹងណា!

ក៖ ចាស!

ខ៖ បាទ!

ក៖
កាលនៅក្នុងជំនាន់រាស្រ្តជានិយមលោកតាបានអើយ!...ដូចជាក្រៅពីនឹងអីនឹងមាននៅក្នុងសម័យជុនណុលអីនឹងដែលគេបានធ្វើការទំលាក់គ្រាប់បែបអីនឹងចឹងដែរទៅកាលនុងចឹង!

ខ៖ កាលលំបាកនឹងវាបានចេះតែផុតៗនឹងមក!

ក៖
ចាស!ហើយចុះចំពោះពេលនៅក្នុងសម័យពពតនឹងកាលនុងលោកតាត្រូវបានគេនឹងជំលៀសលោកតាទៅឯណាដែរកាលនុង?

ខ៖
កាលនៅក្នុងសម័យពពតនឹងកាលនុងលោកតាគេនឹងធ្វើការជំលៀសទៅ...កាលនឹងនៅក្នុងជំនាន់ពពតនឹងកាលនឹងអ្នកស្រុកនឹងអ្នកភូមិនឹងកាលនុងគេបានជំលៀសទៅឆ្ងាយនឹងបានខ្លះអ្នកខ្លះចឹងទៅក៏គេនឹងបានធ្វើការជំលៀសនឹងទៅដល់កំពង់ធំអីនឹងចឹងដែរនឹងកាលនុងណា!ប៉ុន្មានចំណែកឯខាងរូបខ្ញុំនឹងកាលនឹងគេអត់នឹងបានធ្វើការជំលៀសអីនឹងបានទៅឯណានោះទេកាលនៅឯជំនាន់នឹងនោះ!ព្រោះអីខ្ញុំនឹងគឺជាប្រជាជនចាស់រស់នៅក្នុងនុងចឹងទៅកាលនឹងក៏គេនឹងមិនបានធ្វើការជំលៀសខ្ញុំនឹងចឹងទៅ!

កៈ ដោយសារតែជាអ្នកស្រុកចាស់!

ខៈ បាទ!

កៈ ចាស!កាលនុងគេនឹងបានហៅថាអ្នក១៧មេសាម៉ែន?

ខៈ
បាទ!កាលនុងគេនឹងបានធ្វើការជំលៀសប្រជាជននឹងបានចេញទៅវិញនឹងចឹងទៅកាលនុងចឹង!ហើយចំណែកឯចំពោះប្រជាជនដែលបានរស់នៅឯទីនុងនោះកាលនឹងគេមិនបាននឹងធ្វើការជំលៀសនឹងនោះទេ!

កៈ
ចាស!ចឹងមានន័យថាលោកតានៅ...ប្រចាំជាមួយនឹងស្រុកនៅចាំជាមួយនឹងក្រុមគ្រួសារនឹងទាំងអស់នឹងមិនមានបានបែកបាក់គ្នានោះទេ?

ខៈ
បាទ!កាលនុងបាននៅជាមួយនឹងក្រុមគ្រួសារនឹងទាំងអស់នឹងមិនបានមានបែកបាកគ្នានោះទេកាលនឹងនុងណា!

កៈ ចឹងកាលនឹងនុងគេនឹងបានប្រើអោយលោកតានឹងបានធ្វើអ្វីគេខ្លះដែរនៅក្នុងពេលនឹង?

ខៈ នៅកាលនុងគេដូចថានៅជំនាន់ពពតនឹងដូចថាគ្រួសារ
គេប្រើកាលនឹងនុងតែសំរាប់ចំណែកខ្ញុំនឹងវិញនឹងគេមិនបានប្រើនោះទេគេអត់បានប្រើទេ!
ខ្ញុំនឹងកាលនឹងខ្ញុំនឹងនៅតាមក្រសួងមន្ទី។

កៈ អូ!...

ខៈ
នឹងនៅក្នុងក្រសួងមន្ទីនឹងកាលនឹងដោយសារតែរូបខ្ញុំនឹងកាលនឹងជាជាងដេរនឹងកាលនឹងនុងចឹងពេលនឹងគេនឹងបានអោយយើងនឹងបាននៅក្នុងក្រសួងមន្ទីនឹងចឹងទៅកាលនឹងនុង!យើងនឹងបានដេរជាសាកាដូអីនឹងចឹង!មានបានដេរជា អាវអីនឹងចឹង
ផ្ទាល់ចឹងកាលនឹងខ្ញុំនឹងបាននៅខាងចឹងវិញកាលនឹងនុង។

កៈ អូ!លោកតាចឹង!

ខ៖
ដល់ពេលដែលគេនឹងបានត្រូវការនឹងមកនឹងចឹងទៅកាលនឹងខ្ញុំនឹងជាអ្នកដែលបានដេរអីនឹងសំរាប់អោយគេកាលនឹងបានដេរអីនឹងចឹងសំរាប់នឹងយកទៅអោយខាងទ័ពអីនឹងចឹងទៅណា!

ក៖ ចាស!

ខ៖ បានដេរនឹងអោយខាងជា សាកាដូ
មានអីនឹងចឹងទៅសំរាប់នឹងដាក់គ្រាប់អីនឹងចឹងសំរាប់មានស្ពាយអីនឹងសព្វបែបសព្វយ៉ាងនឹងកាលនឹង!ហើយនឹងមានខោអាវអីនឹងកាលនឹងនុងខ្ញុំនឹងជាអ្នកដែលបានធ្វើខាងនឹងកាលនុង! នៅក្នុងកន្លែងនោះនុង។

ក៖ ហឺ!...ចឹងលោកតាមានគ្នានឹងបានប៉ុន្មាននាក់ដែរនៅពេលធ្វើនឹង?

ខ៖ ការដែលគេនឹងធ្វើការនឹងកាលនឹងគេបានធ្វើការនៅតាមភូមិ។

ក៖ អូ!

ខ៖ គេថាដូចជានៅក្នុង១ឃុំនឹងមាន៦ទៅ៧នាក់
!មួយឃុំនឹងចឹងមានគ្នា៦ទៅ៧នឹងអីនឹងចឹងទៅណា!

ក៖ ចឹងកន្លែងលោកតានឹងកាលនឹងមាន៦ទៅ៧នឹងនាក់អីនឹងចឹងទៅកាលនុង?

ខ៖ នឹងហើយកាលនឹងមាន៦ទៅ៧នឹងចឹងទៅកាលនុង។

ក៖ ចាស!បានសំរាប់នឹងធ្វើការជួយដេរគ្នា!

ខ៖ បាទ!

ក៖
ចុះកាលនុងគេនឹងបានធ្វើការកំណត់អោយលោកតាបានដេរនឹងច្រើនៗដែរឬទេលោកតាកាលនុង?

ខ៖
បាទ!កាលនឹងគេនឹងបានកំណត់ទៅតាមសមរភូមិរបស់គេនឹងបានបង្គប់បញ្ជានឹងមកនឹងកាលនឹងនុងចឹង!ពេលដែលគេនឹងបានបង្គប់អោយយើងនឹងធ្វើនឹងចឹងទៅកាលនឹងយើងនឹងក៏បានធ្វើនឹងសំរាប់អោយដល់គេនឹងចឹងទៅណាចឹងកាលនឹងនុង!

កៈ ចាស! ហឺស!...

ខៈ
ប៉ុន្តែកាលនុងក្រណាត់អីនឹងកាលនឹងនៅ...កាលនឹងមិនបានដឹងថាចំពោះក្រណាត់អីនឹងកាលនឹងមិនបានជាដឹងថាកាលនុងគេនឹងបានដឹកក្រណាត់អីនឹងមកពីណាអីនឹងនោះទេនៅសម័យកាលនុងណា!

កៈ ចាស!

ខៈ អាណឹងរឿងក្រណាត់!

កៈ តែសំរាប់លោកតា! គេមានបានធ្លាប់នឹងធ្វើបាបដល់លោកតាដែរឬទេនៅសម័យកាលនុង?

ខៈ ខ្ញុំនឹងវាអត់បានធ្លាប់គេនឹងធ្វើបាបនោះទេ!

កៈ អត់ដែរទេចឹងហាំ?

ខៈ
អត់ដែរគេនឹងបានធ្លាប់នឹងធ្វើបាបអីនឹងបានពីមុននឹងមកនោះទេ!ហេស!ៗអានេះនឹងខ្ញុំនឹងបាននិយាយនឹងតាមតែសច្ចៈនឹងនេះណា!
កាលនឹងព្រោះអីខ្ញុំនឹងបាននៅតែនៅក្នុងមន្ទីៗនឹងកាលនឹងខ្ញុំនឹងកាលនឹងគេនឹងមិនបានប្រើអោយខ្ញុំនឹងបានទៅឯណានោះទេកាលនឹងគេនឹងបានប្រាប់ដល់ខ្ញុំនឹងថាបើសិនជាតាឯងនឹងបានចេះធ្វើនឹងចឹងទៅកាលនឹងគេនឹងបានអោយយើងនឹងគិតតែនឹងធ្វើជាខោអាវអីនឹងអោយដល់គេនឹងអីនឹងចឹងទៅកាលនុង។

កៈ ហឺ!...

ខៈ
ចឹងពេលដែលថាមានទាញទៅខ្វះខាតអីនឹងរហែតអីចឹងគេនឹងបានចេះតែផ្ញើអីនឹងមកចឹងកាលនឹងហើយយើងនឹងបានចេះតែនឹងដេរអោយប៉ះនឹងអោយហើយចឹងយើងនឹងបានចេះតែនឹងបញ្ជូនអីនឹងបានទៅវិញចឹងទៅណាកាលនឹងសម័យនោះចឹងទៅ!

កៈ ចាស!

ខ៖ ចឹងទៅ!កាលនោះចឹងហើយពេលនឹងសម័យនឹងបានជាខ្ញុំនឹងមិនបាននឹងចេះហាត់នឿយអីនឹងចឹងគេនឹងណាកាលនុងចឹង!

ក៖ ចុះចំពោះអាហារហូបចុកអីនឹងនឹងវិញនោះលោកតា?

ខ៖ ហឹ!...កាលនុងអ្នកដែលគេនឹងបាននៅក្នុងមន្ទីនឹងកាលនឹងមិនបានទៅខ្វះខាតរឿងហូបចុកអីនឹងនោះទេកាលនុងនោះព្រោះអីកាលនឹងបើសិនជាខ្វះនឹងកាលនឹងមានតែអ្នកដែលនៅតាមការដ្ឋាននឹងនៅតាមៗ...រោងបាយរោងអីនឹង!

ក៖ ហឹ!...

ខ៖ នៅតាមរោងបាយអីនឹងហើយ!

ក៖ លោកតាកាលនឹងលោកតានឹងកាលនឹងចឹងមានសំណាងណាស់ចឹង!

ខ៖ បាទ!នឹងកាលនឹងមានសំណាងដែរនឹងបាទ!

ក៖ ហឹ!...ហើយចុះគ្រួសាររបស់លោកតានឹងកាលនឹងអត់មានអីដែរ?

ខ៖ អត់នោះទេ!កាលនឹងចំពោះគ្រួសារអីនឹងកាលនឹងគាត់នឹងបានពិបាកដែរនឹងកាលនឹង! ពេលនឹងខ្ញុំនឹងបានស្រួលនឹងបានរួចខ្លួននឹងតែឯងនឹង!ហេសៗៗ!

ក៖ ហេស!ៗៗ

ខ៖ កាលនឹងគ្រួសារលោកតានឹងបាននៅតាមរោងបាយអីនឹងចឹងដែរនឹងកាលនឹងចឹងបានថាពេលនឹងវាមានលំបាកអីនឹងខ្លះដែរចឹងទៅណា!

ក៖ ចឹងនឹង!

ខ៖ ចឹងកាលនឹងបានហូបជាបបរអីនឹងបានហូបអីនឹងជាបាយអីនឹងចឹងទៅកាលនឹងនុងចឹងវាបានពិបាកអីនឹងខ្លះចឹងទៅ!ចឹងហើយនៅសម័យកាលនឹងចឹងវានឹងជារឿងដូចថាធម្មតានឹងទៅហើយនៅសម័យកាលនុងព្រោះអីគេនឹងក៏ចឹងហើយនឹងយើងនឹងក៏ចឹងដែរ!

ប៉ុន្តែនៅសម័យកាលនឹងនុងបានថាវានឹងបានផុតទុក្ខនឹងនៅក្នុងការស្លាប់នឹងហើយកាលនុងអត់អីនោះទេ។

ក៖ តែកាលនឹងគេ...

ខ៖ ដូចជាបានដាច់ភ្លើងហើយអីនឹង!ហាស!

ក៖ អត់អីទេលោកតាអត់មានងងឹតផង!

ខ៖ អូ!ចឹងមានន័យថាដាច់ភ្លើងនឹងម៉ែននឹងចឹងបានជាងងឹតចឹង!
មើលដាច់ឡើងអស់រលីង!ចឹងមុននឹងមិញនឹងយើងនឹងមិនបាននឹងបានបើកអានឹង!

ក៖ ចាស!

ខ៖ ដាច់ភ្លើងអស់ឡើងងងឹត!

ក៖ អត់អីទេមើលឃើញតើ!

ខ៖ អូ!ចឹងបានជាវារាងភ្លៅ!

ក៖ ចុះ
លោកតាចឹង!កាលនឹងលោកតាបានធ្លាប់ឃើញគេនឹងបានយកមនុស្សនឹងទៅសំលាប់ចោលដែរឬទេលោកតា?

ខ៖ យកមនុស្សនឹងទៅសំលាប់ចោល?

ក៖ ចាស!ពួកអាពតនឹងណា!កាលនុង!

ខ៖ ខ្ញុំនឹងកាលនឹងបានឃើញ!

ក៖ លោកតាបានឃើញនឹងដោយផ្ទាល់ភ្នែកនឹងតែម្តងហ៎លោកតា?

ខ៖
ហោស!ៗកាលនឹងខ្ញុំនឹងបានឃើញនឹងមិនបាននឹងមើលឃើញនឹងនៅវារាងបានជិតនោះទេកាលនឹងពេលនឹងខ្ញុំនឹងបានមើលឃើញនឹងវារាងថាឆ្ងាយដែរនឹងកាលនឹងព្រោះអីពេលនឹងបានមើលឃើញគេនឹងបានដឹងមនុស្សនឹងយកទៅចឹង!ណា!ហើយចឹងនៅត្រង់នៅក្នុងសាលាគំរូនឹងកាលនឹងបានមើលឃើញស្នាមឈាមដៃនឹងឡើងនៅអូសចឹងណា!នៅតាមពិដានជញ្ជាំងសាលាអីនឹងណា!

ក៖ អូ!...

ខ៖ បាទ!
ហើយនឹងកាលនឹងនៅតាមជិតសាលានឹងកាលនឹងគេនឹងបានជីករន្ធដៅនឹងកាលនឹងឡើងជ្រៅៗនឹងកាលនឹងនៅតាមនឹង!ចឹងពេលដែលគេនឹងបានដាក់អង្គាមនឹងហើយគេនឹងបានដុតអង្គាមនឹងណាហើយចឹងគេនឹងបានកប់នឹងអង្គាមនឹងចឹងទៅ!

ក៖ អូ!...ចឹង!

ខ៖
នឹងហើយ!អឺហ៊ឺសវានឹង...កាលនឹងគេនឹងបានយកមកវ៉ៃចោលនៅឯសាលាគំរូនឹងបានច្រើននាក់ដែរ។

ក៖ ហ៊ឺ!...

ខ៖ បានដាច់ភ្លើងនឹងបាត់!

ក៖
ចាស!អូ!ចឹងលោកតាចឹងសរុបមកលោកតាសំរាប់បទពិសោធន៍ល្អៗវិញនឹងតើលោកតាមានបានធ្លាប់ជួបនឹងបទពិសោធន៍ល្អៗអីគេខ្លះនៅក្នុងជីវិតរបស់លោកតា?

ខ៖ នៅក្នុង១ឆាកជីវិតនេះ ចំពោះខ្ញុំនឹង...បទពិសោធន៍ល្អៗដូចជាអើ!វាថាដូចជាទៅតាមនឹងមុខជំនាញនឹងទៅតាមការរកស៊ីនឹងណា!ខ្ញុំនឹងបានបែកនឹងហើយនឹងកាលនឹងខ្ញុំនឹងបានទៅធ្វើការងារស្រែនឹងនៅឯខាងស្រុករបស់ខ្ញុំនឹងកាលនុងចឹងពេលនឹងខ្ញុំនឹងបានមានការហត់នឿយអីនឹងបានគ្រប់នឹងបែបយ៉ាងនឹងហើយកាលនឹងមានការលំបាកអីនឹងបានគ្រាប់បែបនឹងគ្រាប់យ៉ាងនឹងហើយកាលនុងដើម្បីនឹងជិវិតនឹងណាកាលនុងចឹងកាលនឹងមិនបាននឹងគិតបាបនឹងគិតបុណ្យអីនឹងនោះទេ!

ក៖ ចាស!

ខ៖
បាទ!បានកាលនឹងនោះនឹងបានម៉ាឆ្លងកាត់នឹងបានខំប្រឹងនឹងរកស៊ីអីចឹងទៅនឹងគេនឹងឯងអីនឹងចឹងទៅកាលនឹងចឹងហើយបានតខ្ញុំនឹងបានមកចូលវត្តនឹងចូលវ៉ាអីនឹងចឹងទៅបានជាឈប់នឹងលែងចាកអំពីបាបកម្មអីនឹងចឹងទៅ!

កៈ ហឺ!...

ខៈ មានអីនោះទៀត?

កៈ
ចាស!លោកតាចឹងលោកតាបានចាំបទពិសោធន៍ល្អៗរបស់លោកតានឹងមានតែប៉ុណ្ណឹងនោះទេលោកតានឹងតាំងពីតូចនឹងមក?

ខៈ មានតែប៉ុណ្ណឹងនោះទេ!

កៈ
អូ!...ចឹងជាចុងក្រោយនឹងតើលោកតាមានពាក្យពេជ្យអ្វីដែរសំរាប់នឹងធ្វើការផ្តាំផ្ញើដល់កូនចៅជំនាន់ក្រោយ?

ខៈ
អូ!...សាធូក្មួយអើយ!បានជាតានឹងមានពាក្យពេជ្យនឹងសំរាប់ធ្វើការផ្តែផ្តាំនឹងជាចុងក្រោយនឹងខ្ញុំនឹងសូមផ្តែផ្តាំដល់កូនចៅជំនាន់ក្រោយនឹងគឺកុំអោយកសាងអំពើអាក្រក់!គិតតែថាយ៉ាងម៉េចនឹងគឺកសាងតែអំពើល្អទៅដូចថាសង្គមយើងនឹងនៅពេលឥឡូវយើងនឹងបានដូចជាលោកតាបានមើលឃើញហើយណ៎!ចឹងថាសង្គមយើងនឹងដូចថាវានឹងបានរហ័សនឹងរហួនណាស់សុទ្ធតែក្មេង!ៗនឹងមិនបានជាសូវបានអាយុនឹងបាននៅវែងអីនឹងបានប៉ុន្មាននោះទេ!បានតែអាយុ៦០អីនឹងបាន៦០លើនឹង៦០ចុះអីនឹងមិនបានជាខ្លះនឹងដល់ផងនឹងហើយមើលកំរនឹងមានបានអាយុនឹងបាន៨០ឆ្នាំណាស់ឥឡូវណាស់នឹង!ចឹងខ្ញុំនឹងបានសូមផ្តែផ្តាំដល់កូនចៅជំនាន់ក្រោយនឹងបានធ្វើការងារប្រព្រឹត្តិតែអំពើនឹងល្អទៅកុំទៅប្រព្រឹត្តិអំពើអាក្រក់អី!ការផ្តាំផ្ញើនឹងមានតែចឹងនោះទេណា!បាទ!

កៈ
ចាស!លោកតាចាស!ចឹងលោកតាជាទីបញ្ចប់នឹងតើលោកតាធ្វើការអនុញ្ញាតអោយខ្ញុំនឹងធ្វើការដាក់សំលេងរបស់លោកតាមុននឹងនៅក្នុងវេសាយរបស់សាលាដែរឬទេ?...

ខៈ មិនបាច់ទេហេស៎?

កៈ
អោយគេនឹងបានដូចជាអឺ...កូនចៅជំនាន់ក្រោយនឹងគេបានស្លាប់នឹងដែរចឹងណា!ព្រោះអីបើសិនជាអត់បានដាក់នៅក្នុងវេបសាយរបស់ខាងសាលានឹងចឹងគេខាងក្រោយនឹងមកទៀតនឹង

ដូចជាកូនចៅជំនាន់ក្រោយនឹងមកទៀតនឹងគេមិនអាចនឹងធ្វើការស្តាប់នូវកិច្ចសំភាសន៍របស់លោកតាមួយនឹងអត់បាននោះទេ!

ខ៖ ហេស!

ក៖
ចឹងពេលដែលបានដាក់នៅក្នុងវេបសាយរបស់ខាងសាលាទៅវាជួយអោយកូនចៅជំនាន់ក្រោយនឹងគេនឹងអាចសើរើនូវជីវៈប្រវិត្តជីវិតរបស់ខាងលោកតាបាន!ឧទាហរណ៏ដូចជាកូនចៅរបស់លោកតាផ្ទាល់!

ខ៖
ខ្ញុំនឹងនឹកគ្រែងឡេាថាពេលខ្ញុំនឹងបានឆ្លើយទៅនឹងវាមិនសូវជាសមអីនឹងចឹង!យ៉ាងណាៗអីនឹងវា...

ក៖
អូ!...អត់អីនោះទេលោកតានៅពេលខាងក្រោយនឹងមកទៀតនឹងខាងគំរោងនឹងគេនឹងមានជាឌីសសំរាប់នឹងយកអោយលោកតាដើម្បីនឹងយកអោយលោកតាបានស្តាប់នឹងចឹងដែរណា!ហើយយើងនឹងនូវមិនទាន់ធ្វើការUploadសំលេងរបស់លោកតានឹងភ្លាមៗនឹងនៅខាងក្នុងវេបសាយនឹងនោះទេ!ព្រោះអីយើងនឹងត្រូវការសំការអនុញ្ញាតពីលោកតាសិនហើយនឹងសំរាប់ឌីសនឹងអោយលោកតានៅពេលខាងក្រោយនឹងទៀត!សំរាប់ឌីសសំលេងនៅក្នុងថ្ងៃនេះនឹងណា!ចឹងហើយលោកតានឹងអាចនឹងបានស្តាប់សំលេងរបស់លោកតានៅក្នុងការសំភាសន៍នៅក្នុងថ្ងៃនេះបាន។
ហើយសំរាប់សំណួរនឹងចម្លើយទាំងអស់នឹងលោកតានឹងអាចអឺ...លោកតានឹងអាចដឹងថាពេលដែលលោកតាបាននិយាយនឹងវាយ៉ាងម៉េចដែរ?ព្រោះអីរឿងទាំងអស់នឹងវាជារឿងពិតដែរលោកតាបាននិយាយ!

ខ៖ រឿងពិត ជារឿងពិត!

ក៖ ចាស!

ខ៖ បាទ!

ក៖ នឹងហើយ!

ខ៖
តាមពិតនឹងនោះទេវាអត់នឹងមានទៅ!...ព្រោះអីបើសិនជាបានរស់នៅនឹងតាមដំណើរជីវិតនឹងវាចឹងមក!

ក៖
ចាស!ចឹងកូនចៅជំនាន់ក្រោយនឹងមកទៀតនឹងគេនឹងបានចង់ដឹងអំពីជីវិតពិតរបស់លោកតានឹងចឹងណា!
ដូចជាខ្ញុំនឹងអីនឹងអត់នឹងបានកើតទាន់នៅក្នុងសម័យរបស់លោកតានោះទេចឹងហើយអត់បានដឹងថាពេលសម័យមុននឹងបានឆ្លងកាត់ការលំបាកអីគេនឹងខ្លះដូចជាការទទួលទានពង្សប្រវិត្តអីនឹងបែបណាអីនឹងអត់នោះទេ!តែសំរាប់នៅក្នុងគំរោងមួយនេះបានជួយអោយលោកតាបានចង់ក្រង់ពង្សប្រវិត្ត ចង់ក្រង់ដូចជាអំពីជីដូនជីតា ឪពុកម្តាយ
អី!...ជីវិតរបស់លោកតាផ្ទាល់នឹងតាំងពីមុននឹងមកនឹងចឹងកូនចៅរបស់លោកតានឹងគាត់អាចនឹងធ្វើការរកឈ្មោះរបស់លោកតានៅក្នុងវេសាយរបស់ខាងសាលានឹងបានចឹង!ដោយគ្រាន់តែខាងសាលានឹងគេនឹងធ្វើការផូសដូចជាសំលេងរបស់លោកតាហើយនឹងរូបថតរបស់លោកតានឹងនៅក្នុងវេបសាយនឹងចឹងណា!នៅក្នុងវេបនឹងចឹងទៅនឹងបានជាគេនឹងអាចនឹងរកវាបានចឹងបើសិនជាគេនឹងមិនបានផូសនឹងនោះទេគេនឹងមិនអាចនឹងស្វែងរកវានឹងបាននោះទេ!ដូចជាវានឹងត្រូវបានបាត់បង់នឹងដែរចឹងណា!

ខ៖ ចឹងចំពោះការដែរខ្ញុំនឹងបានឆ្លើយទៅនឹងចំពោះក្មួយនឹងតើវាយ៉ាងម៉េចដែរ?

ក៖ អឺ!...ខ្ញុំបានស្តាប់ទៅនឹងគឺជារឿងពិតអត់មានអីនឹងទេ
ពេលដែលលោកតានឹងបាននិយាយមកនឹងវាជារឿងរបស់លោកតាវាជារឿងពិតនឹងចឹងណា!ចឹងហើយវាគួរអោយចាប់អាម្មរណ៍មែនទែន ដែលបានទាក់ទងនឹងជីវិតរបស់លោកតា។

ខ៖
អឺ!..នឹងនេះនឹងបានឆ្លើយនឹងទៅតាមដំណើរជីវិតរបស់លោកតានឹងដែរជាជីវិតដែរខ្ញុំនឹងបានមានរហូតមកដល់ពេលសព្វថ្ងៃនេះនឹងណា!

ក៖ ចាស!ចឹងលោកតាអនុញ្ញាតអោយដាក់នៅក្នុងខាងវេបសាយរបស់ខាងសាលាដែរឬទេ?

ខ៖
អនុញ្ញាតអោយដាក់នឹងហើយថាដាក់ក៏ដាក់ទៅនឹងតែថាអោយមើលផង!ថាវានឹងគួតែដាក់តែនឹងឬក៏វានឹងយ៉ងម៉េច!

ក៖ ចាស!លោកតាចាស!អរគុណ!

ខ៖ តើមានយើងនឹងបានឆ្លើយទៅនឹងបានចំអាក្រក់អីនឹងនៅឯកន្លែងណា!ទេឬយ៉ាងម៉េច?

ក៖ អត់នោះទេ សំរាប់ដែលខ្ញុំនឹងបានស្តាប់នឹងទៅនោះ!អត់អីនោះផង! ចាស!លោកតាចឹងចៅនឹងធ្វើការស្តាប់វានឹងម្តងទៀតនឹងផងដែរចឹងបើសិនជាយ៉ាងណាអីនឹងចៅនឹងធ្វើការទាក់ទងមកលោកតានឹងធ្វើការយកឌីសអីនឹងបានមកអោយ ដូចថាបើសិនជាវាទាក់ទងនឹងរឿងអីដែរថាវាអត់បានល្អអីនឹងចៅនឹងធ្វើការមិនអាចនឹងគេយកទៅផ្ទូសនោះទេ!ព្រោះអីពេលខ្លះនឹងវានឹងអាចនឹងប៉ះពាល់នឹងចឹងណា!ប៉ុន្តែមុននឹងពេលដែលចៅបានស្តាប់មុននឹងមិញនឹងចៅគិតថាវាអត់មានអីនឹងទេព្រោះអីវាទាក់ទងទៅនឹងជីវិតរបស់លោកតានឹងនឹងផ្ទះអីនឹង!ត្រូវអត់លោកតាដែលលោកតាបានធ្វើការនិយាយមុននឹងមិញនឹង?

ខ៖ ក្រែនឡោតែវានឹងបានខុសអីនឹងនៅកន្លែងណាអីនោះនឹងទេហោស?

ក៖ អត់ផងអត់មានផង!

ខ៖ នឹងហើយពេលដែលនិយាយនឹងបាននិយាយអំពីរឿងនឹងតាមដំណើរជីវិតអីនឹងមានទេណា!

ក៖ ចាស!លោកតាចាស! ចាស!ចឹងថ្ងៃនេះអរគុណលោកតាច្រើនសំរាប់ការចំណាយពេលដើម្បីនឹងអោយចៅធ្វើការសំភាសន៍មួយនេះ។

ខ៖ បាទៗ!